# ការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ)
# នៅប្រទេសកម្ពុជា ÷
# ការវិភាគទៅលើ សិទ្ធិនិន្នាការភេទ
# អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និង
# លក្ខណៈភេទ (សូជីអេសស៊ី)

## សលាកបត្រព័ត៌មាន

RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ស៊ុយអែត
Sverige

# អ្នកនិពន្ធ និងសេចក្តីថ្លែងអំណរគុណ

*សលាកបត្រនេះ រៀបចំបង្កើតឡើងដោយអ្នកស្រាវជ្រាវជាមួយនឹងវិទ្យាស្ថានរ៉ាអ៊ូលវ៉ាលីងប៊ឺក (RWI) ដើម្បីច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌ ក្នុងប្រទេសកម្ពុជា ក្នុងក្របខណ្ឌគម្រោងស្រាវជ្រាវរបស់ RWI ស្តីពីការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) ដោយផ្តោតជាពិសេស ទៅលើសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង (ហៅជារួមថាអ្នកស្រឡាញ់ភេទដូចគ្នា) នៅប្រទេសកម្ពុជា ដែលបានទទួលការគាំទ្រផ្នែកថវិកាពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត (ស៊ីដា)។*

*សលាកបត្រនេះរៀបចំដោយ សារ៉ា ខាទីន (Sarah Cattin) ដែលជាអ្នកស្រាវជ្រាវផ្នែកសិទ្ធិមនុស្ស និងជាទីប្រឹក្សាដែលមានឯកទេសសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ជា លីដា ដែលជាអ្នកស្រាវជ្រាវនិងអ្នកធ្វើការងារអភិវឌ្ឍន៍ នៅក្នុងវិស័យគាំពារសង្គម សមភាពយេនឌ័រ និងការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធផ្សព្វផ្សាយ។ អ្នកស្រាវជ្រាវ RWI ក៏សូមថ្លែងអំណរគុណដល់បណ្ឌិត សេលីន ម៉ាទីន (Céline Martin) និង ផាត់ ឌឺ ប្រ៊ុន (Pat de Brún) ដែលជាទីប្រឹក្សានៃគម្រោងស្រាវជ្រាវនេះ សម្រាប់ការផ្តល់ធាតុចូលដ៏មានតម្លៃបំផុត ក្នុងការរៀបចំបង្កើតសលាកបត្រព័ត៌មានមួយនេះ។ អ្នកស្រាវជ្រាវ RWI ក៏សូមថ្លែងអំណរគុណដល់ លី ពិសី និង ហេង ជ័យលាភី មកពីអង្គការសហគមន៍ឥន្ទធនូកម្ពុជា (ហៅកាត់ថារ៉ក់) ដែលបានផ្តល់ធាតុចូលអំពីសក្តានុពលនានានៃ យូ.ភី.អ ក្នុងការរួមចំណែកដល់ការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា។*

***កំណត់ចំណាំ៖***

*ទស្សនៈនិងយោបល់ដែលបង្ហាញចេញនៅក្នុងការស្រាវជ្រាវនេះ ជាទស្សនៈនិងយោបល់របស់អ្នកនិពន្ធ និងពុំឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ RWI ឬ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត (ស៊ីដា) ឡើយ។*

*ខណៈពេលការបកប្រែជាភាសាខ្មែរត្រូវបានធ្វើឡើងដោយម៉ត់ចត់ប្រកបដោយជំនាញ ការបកប្រែវាក្យសព្ទបច្ចេកទេសមួយ ចំនួន គឺមិនល្អឥតខ្ចោះទេ។ ដូច្នេះ ពាក្យជាអង់គ្លេសត្រូវបានរក្សាទុកក្នុងតង្កៀបសម្រាប់ជាមូលដ្ឋានយោង។*

*ការបកប្រែពាក្យគន្លឹះសំខាន់ៗ ទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ជាភាសាខ្មែរ មិនមែនជាការបកពន្យល់មកពីភាសាអង់គ្លេសទាំងស្រុងនោះទេ។ វាត្រូវបានកែសម្រួលដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នាជាមួយនឹងឯកសារធនធានដែលមានស្រាប់ជាភាសាខ្មែរ ដែលបង្កើតឡើងដោយអង្គការសង្គមស៊ីវិល ដែលមានបទពិសោធន៍ធ្វើការលើប្រធានបទនេះ នៅក្នុងប្រទេសកម្ពុជា។*

*គាំទ្រដោយ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត (ស៊ីដា)*

# តារាងមាតិកា


**បញ្ជីពាក្យបំព្រួញ និងអក្សរកាត់** **4**

**សេចក្តីផ្តើម** **6**

**1. សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និង លក្ខណៈភេទ** **10**

1.1. សន្ទានុក្រមវាក្យសព្ទបច្ចេកទេសសំខាន់ៗ 10

1.2 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ 13

1.3 ទិដ្ឋភាពទូទៅ នៃស្ថានភាពសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងប្រទេសកម្ពុជា 15

**2. ទិដ្ឋភាពទូទៅ នៃយន្តការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ)** **18**

**3. យូ.ភី.អ សម្រាប់ប្រទេសកម្ពុជា៖ ការវិភាគសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ព្រមទាំងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ** **21**

3.1 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ យូ.ភី.អ ជុំទីមួយ សម្រាប់ប្រទេសកម្ពុជា (២០០៩) 21

*យូ.ភី.អ ជុំទី១ សម្រាប់ប្រទេសកម្ពុជា* *21*

*បញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងអំឡុងការពិនិត្យ ជុំទី១ សម្រាប់ប្រទេសកម្ពុជា* *22*

*យូ.ភី.អ ជុំទីមួយ និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក* *22*

3.2 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ យូ.ភី.អ ជុំទីពីរ សម្រាប់ប្រទេសកម្ពុជា (២០១៤) 22

*យូ.ភី.អ ជុំទី២ សម្រាប់ប្រទេសកម្ពុជា* *22*

*បញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងអំឡុងការពិនិត្យ ជុំទី២ សម្រាប់ប្រទេសកម្ពុជា* *23*

*យូ.ភី.អ ជុំទីពីរ និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក* *23*

3.3 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ យូ.ភី.អ ជុំទីបីសម្រាប់ប្រទេសកម្ពុជា (២០១៩) 23

*យូ.ភី.អ ជុំទី៣ សម្រាប់ប្រទេសកម្ពុជា* *24*

*បញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងអំឡុងការពិនិត្យ ជុំទី៣ សម្រាប់ប្រទេសកម្ពុជា* *24*

*យូ.ភី.អ ជុំទីបី និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក* *26*

3.4 ផ្លូវឆ្ពោះទៅមុខសម្រាប់តួនាទីរបស់ យូ.ភី.អ ក្នុងការរួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅប្រទេសកម្ពុជា 27

*3.4.1 ដំណាក់កាលខាងមុខនៃដំណើរការ យូ.ភី.អ នៅកម្ពុជា* *27*

*3.4.2 សក្តានុពលរបស់ យូ.ភី.អ ក្នុងការរួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅប្រទេសកម្ពុជា 29*
*3.4.3 តួនាទីរបស់ភាគីពាក់ព័ន្ធនីមួយៗ ក្នុងការគាំទ្រដល់ការអនុវត្តអនុសាសន៍ យូ.ភី.អ 32*

# បញ្ជីពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| CCHR | Cambodian Center for Human Rights មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CSOs | Civil Society Organizations អង្គការសង្គមស៊ីវិល |
| IBAHRI | International Bar Association's Human Rights Institute វិទ្យាស្ថានសិទ្ធិមនុស្សនៃគណៈមេធាវីអន្តរជាតិ |
| ILGA | The International Lesbian, Gay, Bisexual, Trans and Intersex Association សមាគម ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទ |
| ICCPR | International Covenant on Civil and Political Rights កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ |
| ICESCR | International Covenant on Social Economic and Cultural Rights កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| IOM | International Organization for Migration អង្គការទេសន្តប្រវេសន៍អន្តរជាតិ |
| LGBTIQ+ | Lesbian, Gay, Bisexual, Transgender, Intersex and Queer ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង (ហៅជារួមថា អ្នកស្រឡាញ់ភេទដូចគ្នា) |
| SOGIESC | Sexual Orientation, Gender Identity and Expression, and Sex Characteristics និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (ហៅកាត់ថា សូជីអេសស៊ី) |
| OHCHR | Office of the High Commissioner for Human Rights ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស |
| RGC | Royal Government of Cambodia រាជរដ្ឋាភិបាលកម្ពុជា |
| RoCK | Rainbow Community Kampuchea អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) |
| UDHR | Universal Declaration of Human Rights សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |

| | | |
|---|---|---|
| UN | United Nations អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Program កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UPR | Universal Periodic Review ការពិនិត្យជាសកលតាមកាលកំណត់ (ហៅកាត់ថា យូ.ភី.អ) |

# សេចក្តីផ្តើម

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់ថា *"មនុស្សទាំងអស់ កើតមកមានសេរីភាពនិងភាពស្មើគ្នាៗ ក្នុងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ"* ។ គោលការណ៍សមភាព និងការមិនរើសអើង មានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ហើយច្បាប់សិទ្ធិមនុស្សអន្តរជាតិ ទទួលស្គាល់និន្នាភេទ និងអត្តសញ្ញាណយេនឌ័រ ថាជាមូលដ្ឋានមួយនៃការការពារពីការរើសអើង[1]។ នៅជុំវិញពិភពលោកនេះ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ បុគ្គលអន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង (ហៅជារួមថា អ្នកស្រឡាញ់ភេទដូចគ្នា) បានតស៊ូមតិដើម្បីជំរុញបង្កើនការទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ពួកគេ ក្នុងគោលបំណងដើម្បីរស់នៅរួចចាកផុតពីការរើសអើង និងអំពើហិង្សាផ្អែកទៅលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (ហៅកាត់ថា សូជីអេសស៊ី)[2]។

ក្នុងប្រទេសកម្ពុជា មានការរីកចម្រើនគួរឲ្យកត់សម្គាល់មួយចំនួន លើការយល់ដឹង និងការទទួលយកជាសាធារណៈ ទៅលើអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងអំឡុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយរួមបញ្ចូលទាំងលទ្ធផលដែលកើតចេញពីការលើកកម្ពស់ការយល់ដឹង និងការងារតស៊ូមតិ ដែលអនុវត្តដោយអង្គការសង្គមស៊ីវិល និងសកម្មជនសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដែរ។ ក៏ប៉ុន្តែ ទោះបីមានការរីកចម្រើនដែលគួរឲ្យកោតសរសើរមួយចំនួននេះក៏ដោយ ក៏អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា នៅតែបន្តប្រឈមមុខនឹងទម្រង់ផ្សេងៗនៃការរើសអើងផ្អែកច្បាប់ និងការរើសអើងក្នុងសង្គម ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាយេនឌ័រ/ការបង្ហាញយេនឌ័ររបស់ពួកគេ ដោយរួមបញ្ចូលទាំង ភាពមិនអាចទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះអាពាហ៍ពិពាហ៍របស់ពួកគេ អំពើហិង្សានិងការបដិសេធពីគ្រួសារ ការរើសអើងនិងការធ្វើបាបនៅក្នុងបរិបទអប់រំ ការរើសអើងនៅក្នុងបរិបទការងារ ឧបសគ្គនានាក្នុងការទទួលបានសេវាថែទាំសុខភាពសមស្រប ការមិនអាចទទួលបាននូវការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ និងអំពើហិង្សាផ្អែកលើយេនឌ័រជាដើម[3]។ បទដ្ឋានយេនឌ័រនៃភេទផ្ទុយគ្នានានា ដែលសង្គមចាត់ទុកថាសមស្រប (heteronormative gender norms) និងការយល់ដឹងនៅមានកម្រិតទាបទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ បានរួមចំណែកដល់ការប្រមាថមាក់ងាយ និងការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នា នៅក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជា មិនមានចែងយ៉ាងច្បាស់ អំពីការការពារផ្លូវច្បាប់ប្រឆាំងនឹងការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទនោះទេ។ បន្ថែមពីលើនេះ ប្រព័ន្ធច្បាប់នាពេលបច្ចុប្បន្ន មិនទាន់ទទួលស្គាល់ សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅឡើយទេ ហើយមិនមានច្បាប់ណា ដែលអនុញ្ញាតឲ្យមានការទទួលស្គាល់យេនឌ័រសម្រាប់អ្នកប្តូរយេនឌ័រដែរ។ ខណៈពេលដែលវិធានការមួយចំនួន ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារអ្នកស្រឡាញ់ភេទដូចគ្នាពីការរើសអើង និងអំពើហិង្សា ដោយរួមបញ្ចូលទាំង សេចក្តីថ្លែងការណ៍របស់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកទឹកចិត្តឲ្យសាធារណជន ចៀសវាងការរើសអើងទៅលើអ្នកស្រឡាញ់ភេទ

[1] See details in section 1.2.

[2] See definitions and notes on terminologies about SOGIESC and LGBTIQ+ in section 1.1.

[3] See further details and references in section 1.3

ដូចគ្នាក៏ដោយ ក៏អង្គការសង្គមស៊ីវិលបានគូសបញ្ជាក់ថា កំណែទម្រង់ច្បាប់ និងគោលនយោបាយសំខាន់ៗ គឺជាតម្រូវការចាំបាច់ក្នុងការការពារសិទ្ធិស្មើភាពគ្នារបស់ប្រជាជនកម្ពុជាដែលស្រឡាញ់ភេទដូចគ្នា[4]។

ការពិនិត្យជាសកលតាមការកំណត់ (យូ.ភី.អ) គឺជាយន្តការសិទ្ធិមនុស្សមួយ របស់អង្គការសហប្រជាជាតិ ដែលរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ពិនិត្យការប្រតិបត្តិរបស់រដ្ឋជាសមាជិកផ្សេងទៀត ចំពោះកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ និងផ្តល់អនុសាសន៍ សម្រាប់ការកែលម្អស្ថានភាពសិទ្ធិមនុស្ស[5]។ គោលបំណងដែលបានចែងអំពីយន្តការយូ.ភី.អ គឺការធ្វើឲ្យកាន់តែប្រសើរដល់ស្ថានភាពសិទ្ធិមនុស្ស ក្នុងប្រទេសនីមួយៗ។ យន្តការយូ.ភី.អ ធ្វើការវាយតម្លៃអំពីអនុលោមភាពរបស់រដ្ឋ ជាមួយនឹងកាតព្វកិច្ចសិទ្ធិមនុស្សទាំងអស់របស់ខ្លួន ក្នុងការដោះស្រាយបញ្ហាប្រឈមសិទ្ធិមនុស្សជាច្រើន ឧទាហរណ៍ ដូចជា សេរីភាពបញ្ចេញមតិ សិទ្ធិជនជាតិដើមភាគតិច សិទ្ធិស្ត្រី សិទ្ធិកុមារ ការការពារអ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទផងដែរ។ ប្រទេសកម្ពុជា បានឆ្លងកាត់ការពិនិត្យក្រោមយន្តការយូ.ភី.អនេះចំនួនបីដងរួចមកហើយ ដែលជុំទីមួយធ្វើឡើងនៅក្នុងឆ្នាំ២០០៩ ជុំទីពីរឆ្នាំ២០១៤ និងថ្មីៗនេះ ជុំទីបីសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩។ ក្នុងឆ្នាំ២០១៩ នាអំឡុងពេលនៃការពិនិត្យលើកទីបីនេះ ប្រទេសកម្ពុជាបានទទួលយក ជាលើកដំបូងនូវអនុសាសន៍ យូ.ភី.អ ចំនួន៩ ដែលផ្តោតជាក់លាក់ទៅលើការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ជាពិសេស អនុសាសន៍ស្តីពីការអនុម័តច្បាប់ និងគោលនយោបាយ ដើម្បីធានាការការពារពីការរើសអើងផ្អែកលើមូលដ្ឋានសូជីអេសស៊ី ការបង្កលក្ខណៈអំណោយផលដល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា និងការបង្កើតច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកប្តូរយេនឌ័រ[6]។

ការទទួលយកអនុសាសន៍ទាំងអស់នេះ កើតឡើងខណៈដែលអង្គការសង្គមស៊ីវិលនៅកម្ពុជាដែលធ្វើការលើសិទ្ធិសូជីអេសស៊ី បានចូលរួមនៅក្នុងដំណើរការ យូ.ភី.អ ដែលជាផ្នែកមួយនៃការតស៊ូមតិដើម្បីឲ្យមានការការពារសិទ្ធិស្មើភាពគ្នារបស់ប្រជាជនកម្ពុជាដែលស្រឡាញ់ភេទដូចគ្នា[7]។ ការទទួលយកនូវអនុសាសន៍ យូ.ភី.អ ស្តីពីសូជីអេសស៊ី គឺជាការបង្ហាញនូវការប្តេជ្ញាចិត្តដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងក្របខណ្ឌនៃយូ.ភី.អ ដើម្បីជំរុញបន្ថែមដល់ការកែទម្រង់ច្បាប់ និងគោលនយោបាយទាំងឡាយ ដើម្បីការពារសិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ សលាកបត្រព័ត៌មាននេះ ធ្វើការវិភាគទៅលើការដាក់បញ្ចូលសិទ្ធិសូជីអេសស៊ី នៅក្នុងយូ.ភី.អ របស់ប្រទេសកម្ពុជា និងពិភាក្សាបន្ថែមទៀតទៅលើសក្តានុពលនៃយន្តការយូ.ភី.អ ក្នុងការចូលរួមចំណែកដល់ការការពារសិទ្ធិសូជីអេសស៊ី ក្នុងប្រទេសកម្ពុជា ក៏ដូចជាតួនាទីរបស់ភាគីពាក់ព័ន្ធសំខាន់ៗ នៅក្នុងការចូលរួមក្នុងដំណើរការនេះ ដើម្បីរួមចំណែកដល់ការធ្វើឲ្យមានការរីកចម្រើនដល់ការការពារសិទ្ធិសូជីអេសស៊ី និងសិទ្ធិមនុស្ស។

---

[4] See further details in section 1.3. See also : Civil Society UPR Joint Submission: 'Joint Submission to the UN Human Rights Council for the Third Universal Periodic Review of the Kingdom of Cambodia. SOGIESC & SRHR in Cambodia', (2018) available at https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf.
Joint Statement By Civil Society Organizations: Step Up Efforts To Protect The Rights Of Lesbian, Gay, Bisexual, Transgender, Intersex, Queer (LGBTIQ) People In Cambodia, In Line With The Universal Periodic Review Recommendations Accepted By Cambodia. (27 September 2021) https://rockcambodia.org/joint-statement-upr-mtr-2021/

[5] See details in section 2.

[6] See details in section 3.3

[7] See section 3.4.2.

*គោលបំណងនិងក្រុមគោលដៅនៃសលាកបត្រព័ត៌មាន៖*

សលាកបត្រព័ត៌មាន រៀបរាប់ពីព័ត៌មាន និងឯកសារសំខាន់ៗមួយចំនួនស្តីពី យូ.ភី.អ និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ក្នុងប្រទេសកម្ពុជា[8]។ សលាកបត្រនេះ មានគោលបំណងចងក្រងឯកសារយោងមួយ សម្រាប់គ្រូបង្រៀនសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ និស្សិតសាកលវិទ្យាល័យនៅប្រទេសកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីប្រធានបទនេះ។ សលាកបត្រនេះ ក៏មានបំណង ធ្វើជាឯកសារពិគ្រោះសំខាន់មួយ ក្នុងការគាំទ្រដល់ការងាររបស់អង្គការសង្គមស៊ីវិលនានា ដែលចូលរួមជាមួយនឹងដំណើរការ យូ.ភី.អ នេះផងដែរ។

សលាកបត្រព័ត៌មាននេះ ណែនាំអំពីទស្សនៈនានាស្តីពីតួនាទីនិងសក្តានុពលនៃយន្តការ យូ.ភី.អ សម្រាប់ការការពារសិទ្ធិមនុស្ស ជាពិសេស សិទ្ធិសូជីអេសស៊ី ក្នុងប្រទេសកម្ពុជា។ សលាកបត្រនេះ ក៏រួមចំណែក បង្កើនការយល់ឱ្យកាន់តែប្រសើរ របស់ភាគីពាក់ព័ន្ធសំខាន់ៗ អំពីសក្តានុពលនៃតួនាទីរបស់ពួកគេ ក្នុងការចូលរួម និងរួមចំណែកក្នុងដំណើរការ យូ.ភី.អ នេះ។

សលាកបត្រព័ត៌មាន ផ្តោតលើក្រុមគោលដៅដូចជា៖

- **និស្សិតសាកលវិទ្យាល័យ** ដោយរួមបញ្ចូលទាំងនិស្សិតផ្នែកច្បាប់ ប្រព័ន្ធផ្សព្វផ្សាយ ទំនាក់ទំនងអន្តរជាតិ និងវិទ្យាសាស្ត្រសង្គម។ សលាកបត្រផ្តល់ជាប្រភពធនធានមួយសម្រាប់និស្សិតសាកលវិទ្យាល័យ ក្នុងការបង្កើនការយល់អំពីប្រធានបទទាំងនេះ ព្រមទាំងបញ្ចូលបញ្ជីឯកសារយោងបន្ថែម ដែលបង្កលក្ខណៈងាយស្រួលសម្រាប់សិស្សនិស្សិត ប្រសិនបើពួកគេមានចំណាប់អារម្មណ៍ការសិក្សាបន្ថែម។
- **គ្រូបង្រៀនសាកលវិទ្យាល័យ** ដោយរួមបញ្ចូលទាំងគ្រូ សាស្ត្រាចារ្យ ផ្នែកសិទ្ធិមនុស្ស ច្បាប់ ទំនាក់ទំនងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយ។ សលាកបត្រ ជាធនធានឯកសារមួយ ដែលផ្តល់ឲ្យគ្រូនៅសាកលវិទ្យាល័យ ទទួលបាននូវទិដ្ឋភាពទូទៅលើប្រធានបទទាំងនេះ ដែលអាចជួយគាំទ្រពួកគាត់ក្នុងការរៀបចំមេរៀនសម្រាប់បង្រៀន រៀបចំសិក្ខាសាលា ឬគម្រោងសិក្សាទៅលើប្រធានបទទាំងអស់នេះ។
- **អ្នកស្រាវជ្រាវ៖** សលាកបត្រនេះ ផ្តល់ជាសេចក្តីផ្តើមណែនាំមួយ លើប្រធានបទទាំងអស់នេះ និងផ្តល់ជាចំណុចដៅច្បាស់លាស់សម្រាប់ចាប់ផ្តើមការស្រាវជ្រាវបែបស៊ីជម្រៅបន្ថែមទៀត ទៅលើប្រធានបទសិទ្ធិមនុស្សទាំងអស់នេះ ដើម្បីឲ្យអ្នកស្រាវជ្រាវក្នុងប្រទេសកម្ពុជា អាចពិចារណាក្នុងការវិភាគលើប្រធានបទទាំងនេះបន្ថែមទៀត ព្រមទាំងបំពេញចន្លោះខ្វះខាតចំណេះដឹងក្នុងការស្រាវជ្រាវដែលមានស្រាប់។
- **អង្គការសង្គមស៊ីវិលកំពុងធ្វើការទាក់ទងនឹងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី)៖** សលាកបត្រ មានការវិភាគលម្អិតអំពីការដាក់បញ្ចូលសិទ្ធិសូជីអេសស៊ី នៅក្នុងដំណើរការយូ.ភី.អ ទាំងអស់របស់ប្រទេសកម្ពុជា ហេតុដូច្នេះហើយ វាបង្កើតបានជាធនធានឯកសារពិគ្រោះដ៏មានសារៈប្រយោជន៍មួយ និងជាឯកសារយោងមួយសម្រាប់អង្គការសង្គមស៊ីវិល ក្នុងការធ្វើសកម្មភាពរបស់ខ្លួនដែលទាក់ទងទៅនឹងការចូលរួមជាមួយដំណើរការយូ.ភី.អ ដោយ

[8] See definition of key concepts in Section 1.1

រួមបញ្ចូលទាំង ការរៀបចំរបាយការណ៍ក្នុងក្របខណ្ឌ យូ.ភី.អ ក្នុងពេលអនាគតទៀតផង។ ជាការគួរឲ្យកត់សម្គាល់សលាកបត្រនេះ មានបញ្ចូលនូវទិដ្ឋភាពទូទៅយ៉ាងលម្អិត អំពីរដ្ឋភាគីដែលបានលើកពីសិទ្ធិសូជីអេសស៊ី នៅក្នុងដំណើរការយូ.ភី.អ ទៅលើប្រទេសកម្ពុជា ដែលអាចផ្តល់ព័ត៌មានបន្ថែមដល់អង្គការសង្គមស៊ីវិល សម្រាប់ការរៀបចំយុទ្ធសាស្ត្រតស៊ូមតិក្នុងពេលអនាគតផងដែរ។

សលាកបត្រព័ត៌មាននេះ ក៏អាចមានប្រយោជន៍សម្រាប់ក្រុមគោលដៅផ្សេងទៀតដែរ ដូចជា៖

- **អ្នកសារព័ត៌មាន និងអ្នកធ្វើការវិស័យប្រព័ន្ធផ្សព្វផ្សាយ៖** សលាកបត្រនេះ ក៏អាចជាប្រភពធនធានព័ត៌មានសម្រាប់អ្នកធ្វើការវិស័យប្រព័ន្ធផ្សព្វផ្សាយ ដែលរាយការណ៍អំពី យូ.ភី.អ និងសិទ្ធិសូជីអេសស៊ី ក្នុងប្រទេសកម្ពុជា ជាពិសេសជុំវិញការរាយការណ៍ពាក់កណ្តាលអាណត្តិរបស់យូ.ភី.អ ក្នុងខែមករា/កុម្ភៈ ឆ្នាំ២០២២ ឬ ដំណើរការយូ.ភី.អ ជុំបន្ទាប់របស់ប្រទេសកម្ពុជាដែលនឹងត្រូវធ្វើឡើងក្នុងឆ្នាំ ២០២៤។
- **រដ្ឋភាគីដែលផ្តល់អនុសាសន៍៖** រដ្ឋដែលផ្តល់អនុសាសន៍ គឺជាភាគីសំខាន់មួយ នៅក្នុងដំណើរការ យូ.ភី.អ នេះ។ សលាកបត្រនេះ ក៏បញ្ចូលព័ត៌មានសាវតារជាប់ទាក់ទងមួយចំនួន សម្រាប់ជាព័ត៌មានដល់ការងាររបស់ពួកគេ និងដល់ការចូលរួមពាក់ព័ន្ធទៅនឹង យូ.ភី.អ និងសិទ្ធិសូជីអេសស៊ី នៅក្នុងប្រទេសកម្ពុជាដែរ។

*គ្រោងមាតិការបស់សលាកបត្រព័ត៌មាននេះ៖*

សលាកបត្រនេះ បង្ហាញជាដំបូង សេចក្តីដើមណែនាំអំពីពាក្យគន្លឹះបច្ចេកទេសមួយចំនួនអំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ដោយរួមបញ្ចូលនិយមន័យសំខាន់ៗ ទិដ្ឋភាពទូទៅនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិទាក់ទងទៅនឹងសិទ្ធិសូជីអេសស៊ី ក៏ដូចជា ទិដ្ឋភាពទូទៅអំពីស្ថានភាពសិទ្ធិសូជីអេសស៊ី ក្នុងប្រទេសកម្ពុជា (ផ្នែកទី១)។ បន្ទាប់មក សលាកបត្រ ណែនាំអំពី យូ.ភី.អ ដែលជាយន្តការមួយសម្រាប់ការពារសិទ្ធិមនុស្ស (ផ្នែកទី២)។ បន្ទាប់មកទៀត សលាកបត្រនេះ រៀបរាប់អំពី យូ.ភី.អ របស់ប្រទេសកម្ពុជា ជាពិសេស ទាក់ទងជាមួយនឹងសិទ្ធិសូជីអេសស៊ី ក្នុងដំណើរការ យូ.ភី.អ ទាំងបីរបស់ប្រទេសកម្ពុជា ព្រមទាំងបញ្ចូលការវិភាគលម្អិត អំពីវិសាលភាពដែលសិទ្ធិសូជីអេសស៊ី ត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃដំណើរការ យូ.ភី.អ នេះ (ផ្នែកទី ៣.១, ៣.២, និង ៣.៣)។ ចុងក្រោយ សលាកបត្រនេះ បញ្ជាក់អំពីសក្តានុពលនិងទិសដៅក្នុងអនាគតមួយចំនួនរបស់យន្តការ យូ.ភី.អ ក្នុងការរួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងប្រទេសកម្ពុជា។ (ផ្នែកទី ៣.៤)។

# 1. សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ

## 1.1. សន្ទានុក្រមវាក្យសព្ទបច្ចេកទេសសំខាន់ៗ

### និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី)[9]

- **និន្នាការភេទ៖** សំដៅលើទំនោរ ឬ មនោសញ្ចេតនា ឬ អារម្មណ៍ស្នេហារបស់បុគ្គលម្នាក់ ទៅលើបុគ្គលម្នាក់ទៀតដែលមានអត្តសញ្ញាណយេនឌ័រ និងភេទផ្សេងគ្នា ឬ ដូចគ្នា។
- **យេនឌ័រ៖** សំដៅលើតួនាទី អាកប្បកិរិយា សកម្មភាព ឬលក្ខណៈសម្បត្តិនានា ដែលបង្កើតឡើងដោយសង្គមណាមួយ និងត្រូវបានចាត់ទុកថាមានភាពសមស្រប សម្រាប់បុរសនិងស្ត្រី ឬសម្រាប់យេនឌ័រផ្សេងទៀត។
- **អត្តសញ្ញាណយេនឌ័រ៖** សំដៅលើការកំណត់ខ្លួនឯង ដោយផ្អែកលើអារម្មណ៍ខាងក្នុងយ៉ាងជ្រាលជ្រៅអំពីយេនឌ័ររបស់ខ្លួន ដែលអាចស្រប ឬ ផ្ទុយពីភេទពីកំណើតរបស់បុគ្គល។
- **ការបង្ហាញយេនឌ័រ៖** សំដៅលើការបង្ហាញឲ្យឃើញពីរូបរាងខាងក្រៅ នៃយេនឌ័ររបស់បុគ្គលណាម្នាក់តាមរយៈអាកប្បកិរិយា ឥរិយាបថ សំឡេង ការស្លៀកពាក់ ការតុបតែង មុខមាត់ ការជ្រើសរើសឈ្មោះ និងសព្វនាមដើម្បីកំណត់អត្តសញ្ញាណខ្លួនឯង។
- **លក្ខណៈភេទ៖** សំដៅលើលក្ខណៈជីវសាស្ត្រ និងរាងកាយដែលកំណត់ភេទប្រុស ឬស្រី តាមរយៈលក្ខណៈជីវសាស្ត្រចម្បង ឧទាហរណ៍ ប្រដាប់ភេទខាងក្នុងនិងខាងក្រៅ និង/ឬ រចនាសម្ព័ន្ធក្រូម៉ូសូម និងអ័រម៉ូន និងលក្ខណៈជីវសាស្ត្របន្ទាប់បន្សំ ឧទាហរណ៍ សាច់ដុំ ការរៀបចំសក់ និង មាឌកម្ពស់ជាដើម។

*"មនុស្សទាំងអស់ មានលក្ខណៈដូចគ្នាមួយ៖ គឺថា យើងទាំងអស់គ្នា មាននិន្នាការភេទមួយ និងមានអត្តសញ្ញាណយេនឌ័រមួយ។"* [10]

### សិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង (សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា)[11]

- **ស្ត្រីស្រឡាញ់ស្ត្រី៖** សំដៅដល់ស្ត្រីដែលបានកំណត់មនោសញ្ចេតនា ឬ អារម្មណ៍ទាក់ទាញ ឬស្នេហាជាមួយស្ត្រីម្នាក់ទៀត។

---

[9] The following definitions are based on definitions contained in RoCK and Destination Justice, "Guide to human rights for LGBTIQ in Cambodia", 2015. https://rockcambodia.org/wp-content/uploads/2021/08/HR-LGBT-Guide-FINAL-EN.pdf. Some definitions have been edited to reflect current understanding and include additional terminology, based on consultation with Rainbow Community Kampuchea (RoCK), during preparation of sharing sessions in the framework of RWI project on the UPR and LGBTIQ+ rights in Cambodia in 2021

[10] RoCK and Destination Justice, "Guide to human rights for LGBTIQ in Cambodia", 2015. https://rockcambodia.org/wp-content/uploads/2021/08/HR-LGBT-Guide-FINAL-EN.pdf (English) and https://rockcambodia.org/wp-content/uploads/2021/08/Guide-to-H.R-2nd-Edition.pdf (Khmer).

[11] The following definitions are based on definitions contained in RoCK and Destination Justice, "Guide to human rights for LGBTIQ in Cambodia", 2015. https://rockcambodia.org/wp-content/uploads/2021/08/HR-LGBT-Guide-FINAL-EN.pdf. Some definitions have been edited to reflect current understanding and include additional terminology, based on consultation with Rainbow Community Kampuchea (RoCK), during preparation of sharing sessions in the framework of RWI project on the UPR and LGBTIQ+ rights in Cambodia in 2021.

- **បុរសស្រឡាញ់បុរស៖** សំដៅដល់បុរសដែលបានកំណត់មនោសញ្ចេតនា ឬ អារម្មណ៍ទាក់ទាញ ឬស្នេហា ជាមួយបុរសម្នាក់ទៀត។
- **អ្នកស្រឡាញ់ទាំងពីរភេទ៖** សំដៅដល់បុគ្គលដែលមានមនោសញ្ចេតនា ឬ អារម្មណ៍ទាក់ទាញ ឬ ស្នេហា ជាមួយបុរសផង និងស្ត្រីផង។
- **អ្នកប្តូរយេនឌ័រ៖** សំដៅដល់បុគ្គលដែលកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួនឯង តាមរយៈការបង្ហាញខាងក្រៅ ដូចជាការស្លៀកពាក់ និងអាកប្បកិរិយា ដែលផ្ទុយពីភេទកំណើតរបស់ខ្លួន (នេះគឺជាអត្តសញ្ញាណយេនឌ័រ មិនមែនជានិន្នាការភេទទេ)។
- **អន្តរភេទ៖** សំដៅដល់បុគ្គល ដែលកើតមកមានលក្ខណៈជីវសាស្ត្រលាយឡំគ្នានៃភេទប្រុស និងភេទស្រី រួមបញ្ចូលទាំងអ័រម៉ូន ហ្សែន និងក្រូម៉ូសូម និងរូបរាងកាយ។
- **អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង** (Queer)៖ សំដៅដល់បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័ររបស់ខ្លួន មិនស្របទៅតាមការកំណត់និយមន័យនៃភេទប្រុស និងភេទស្រី។ បុគ្គលទាំងនេះអាចកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួននៅចន្លោះរវាង ឬ ក្រៅពី បុរស និងស្ត្រី។ ទ្រឹស្តី Queer បានជំទាស់ទៅនឹង គំនិតដែលទទួលយកតែការស្រឡាញ់ ឬ ទំនាក់ទំនងស្នេហាភេទផ្ទុយគ្នា ថាជាបទដ្ឋាន/ទម្រង់ត្រឹមត្រូវនៃទំនាក់ទំនងផ្លូវភេទ និងយេនឌ័រ ហើយទ្រឹស្តីនេះអះអាងថា ការកំណត់រឿងរ៉ាវផ្លូវភេទ និងយេនឌ័រតែពីរក្រុម (បុរស ឬ ស្ត្រី) បែបនេះ គឺជាបង្កើតឡើងដោយសង្គមតែប៉ុណ្ណោះ។ ក្នុងនាមជាពាក្យដែលគេចាត់ទុកជាពាក្យជេរប្រមាថជារៀងមកនេះ ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា ទាមទារយកពាក្យ Queer មកប្រើឡើងវិញ ដើម្បីពណ៌នាក្រុមរបស់ខ្លួន។ ពាក្យនេះ ក៏ជាពាក្យដែលមនុស្សមួយចំនួន យកមកប្រើជាចង្កោមពាក្យសម្រាប់សម្គាល់អ្នក ស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រ ផងដែរ។ ពាក្យនេះក៏ត្រូវបានប្រើប្រាស់សម្រាប់អ្នកដែលមិនចង់ដាក់ខ្លួនក្នុងប្រអប់អត្តសញ្ញាណណាមួយ។ មិនមែនមនុស្សទាំងអស់ សុទ្ធតែចូលចិត្តប្រើពាក្យនេះទេ ដូចនេះអ្នកគួរសាកសួរបុគ្គលផ្ទាល់ខ្លួន មុននឹងហៅគេថាជា Queer ។
- **យេនឌ័រដែលពុំស្ថិតក្នុងចំណោមយេនឌ័រទាំងពីរ/ យេនឌ័រដែលពុំស្របនឹងយេនឌ័រពីកំណើត/ យេនឌ័រដែលពុំមែនជាភេទប្រុស ឬស្រី** (Gender Non-binary/Genderqueer)៖ សំដៅដល់បុគ្គលដែលមានអត្តសញ្ញាណ និង/ឬ ការបង្ហាញយេនឌ័ររបស់ខ្លួន មិនអនុលោមតាមអត្តសញ្ញាណយេនឌ័រពីរ ជាបុរស ឬស្ត្រី។ បុគ្គលទាំងអស់នេះអាចកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួន នៅចន្លោះរវាងបុរស ឬ ស្ត្រី ឬ នៅក្រៅយេនឌ័រទាំងពីរនេះទាំងស្រុង ក៏ថាបាន។

មិនមែនមនុស្សគ្រប់គ្នាដែលមិនស្រឡាញ់ភេទផ្ទុយគ្នា ឬ មិនអនុលោមតាមបទដ្ឋានយេនឌ័រភេទផ្ទុយគ្នា សុទ្ធតែកំណត់អត្តសញ្ញាណខ្លួនឯងថា ជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ ឬ អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង នោះទេ។ វប្បធម៌ជាច្រើននៅជុំវិញពិភពលោកដែលរួមបញ្ចូលទាំងជនជាតិដើមភាគតិចផងនោះ ទទួលស្គាល់អត្តសញ្ញាណភេទ និងយេនឌ័រដែលខុសប្លែក សម្រាប់វប្បធម៌ទាំងនោះ ហើយដែលអាចស្ថិតនៅក្រៅវិសាលភាពនៃក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ សញ្ញា "បូក" នៅក្នុងពាក្យបំព្រួញ "LGBTIQ+" មានបំណងបង្ហាញនូវការបញ្ចូលឲ្យកាន់តែទូលំ

ទូលាយទៅលើមនុស្សដែលមាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ផ្សេងទៀត និងដើម្បីឆ្លុះបញ្ចាំងនូវវិសាលភាពដ៏ទូលំទូលាយនៃសូជីអេសស៊ី ដែលមានស្រាប់។

មនុស្ស និងអង្គការផ្សេងៗគ្នា អាចប្រើប្រាស់ ពាក្យបំព្រួញជាភាសាអង់គ្លេសផ្សេងៗ ដូចជា "LGBT+" "LGBTI" "LGBTQ" ឬ "ក្រុមភាគតិចផ្នែកផ្លូវភេទ និងយេនឌ័រ (sexual and gender minorities)"។ ប្រភពធនធាននានាដែលបង្ហាញនៅខាងក្រោមនេះ បញ្ជាក់ពីពាក្យពេចន៍សមស្របដែលប្រើនៅក្នុងបរិបទនៃប្រទេសកម្ពុជា ជាភាសាខ្មែរ។

### ប្រភពធនធានបន្ថែមស្តីពីវាក្យសព្ទអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ព្រមទាំងគោលគំនិត ជាភាសាខ្មែរ

- អង្គការរ៉ក់និងអង្គការគោលដៅយុត្តិធម៌ "មគ្គុទេសក៏ស្តីពីសិទ្ធិមនុស្សសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា" (២០១៥) https://rockcambodia.org/guide-to-human-rights-for-lgbt-in-cambodia/
- បទបង្ហាញនិងការពិភាក្សាអំពីវាក្យសព្ទជាភាសាខ្មែរ ទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងអ្នកស្រឡាញ់ភេទដូចគ្នា អាចរកបាននៅក្នុងរបាយការណ៍៖ អង្គការរ៉ក់ (២០១៥) "របាយការណ៍ស្រាវជ្រាវស្តីពីការយល់ឃើញ ឥរិយាបទ និងអាកប្បកិរិយាទៅលើអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។" (ឧបសម្ព័ន្ធ ២) https://www.rockcambodia.org/wp-content/uploads/2020/07/TNS-Research-Report-on-Opinions-Attitudes-and-Behavior-toward-the-LGBT-Population-in-Cambodia.pdf
- វីដេអូស្តីពីនិន្នាការភេទ អត្តសញ្ញាណនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (ជាភាសាខ្មែរ)
    - អង្គការរ៉ក់ "ខ្ញុំចង់ដឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ" https://www.youtube.com/watch?v=19r4uvLoSqQ
    - អង្គការរ៉ក់ "កំប៉ុងជ័រស្ញូជី" https://www.youtube.com/watch?v=r5mgaktkTbk
- ប្រភពធនធានជាភាសាខ្មែរស្តីពី មូលហេតុសំខាន់ក្នុងការគោរពការពេញចិត្តចំពោះ**សព្វនាម** ណាមួយសម្រាប់បុគ្គល https://www.aptby.org/pronouns

### ប្រភពធនធានបន្ថែមស្តីពីវាក្យសព្ទអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ព្រមទាំងគោលគំនិត ជាភាសាអង់គ្លេស

- វាក្យសព្ទនិងគោលគំនិតផ្សេងទៀតដែលទាក់ទងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) និងដែលអាចលេចឡើងក្នុងការពិភាក្សាអំពីសិទ្ធិសូជីអេសស៊ី រួមមានដូចគ្នា "ទំនោរ មនោសញ្ចេតនា ឬអារម្មណ៍ស្នេហារវាងបុគ្គលពីរនាក់ដែលមានអត្តសញ្ញាណយេនឌ័រ និងភេទផ្ទុយគ្នា (heterosexuality); គំនិតដែលកំណត់ថាទំនោរ មនោសញ្ចេតនា ឬអារម្មណ៍ស្នេហា

វាងភេទផ្ទុយគឺជាបទដ្ឋាន/ទម្រង់ត្រឹមត្រូវនៃទំនាក់ទំនងផ្លូវភេទ (heteronormativity); បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រស្របជាមួយភេទពីកំណើត (cisgender); គំនិតដែលសន្មតថាមនុស្សគ្រប់រូបកើតមក មានអត្តសញ្ញាណយេនឌ័រស្របជាមួយនឹងភេទពីកំណើត (cisnormativity); គំនិត អារម្មណ៍ ឬឥរិយាបថអវិជ្ជមាន រើសអើង និងស្អប់ខ្ពើមចំពោះអ្នកស្រឡាញ់ភេទដូចគ្នា (homophobia)"។ ប្រភពខាងក្រោមនេះ រួមមានសន្ទានុក្រមពាក្យនិងគោលគំនិតបន្ថែមទាក់ទងនឹងសូជីអេសស៊ីៈ International Organization for Migration (IOM), "SOGIESC Full Glossary of terms", updated November 2020,
https://www.iom.int/sites/g/files/tmzbdl486/files/documents/IOMSOGIESC-Glossary-of-Terms.pdf

## 1.2 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

**សិទ្ធិទទួលបានការមិនរើសអើង ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់សិទ្ធិមនុស្ស និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ហើយសិទ្ធិនេះ មានរួមបញ្ចូលសិទ្ធិរួចផុតពីការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផងដែរ**[12]។

- **សិទ្ធិទទួលបានសមភាពនិងការមិនរើសអើង** គឺជាគោលការណ៍ស្នូលនៃសិទ្ធិមនុស្សដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិស្នូលនានា រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌[13]។
- ទោះបីជាមិនមានសន្ធិសញ្ញាសិទ្ធិមនុស្សណាមួយរបស់អង្គការសហប្រជាជាតិ លើកឡើងដោយចំពោះអំពីសូជីអេសស៊ី ឬអ្នកស្រឡាញ់ភេទដូចគ្នាក៏ដោយ **ក៏ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបញ្ជាក់ថា និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណោមមូលដ្ឋាននៃការហាមឃាត់ការរើសអើង ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិដែរ**[14]។ ជំហរនេះត្រូវបានបញ្ជាក់ម្តងហើយម្តងទៀត នៅក្នុងសេចក្តីសម្រេច និងមគ្គុទ្ទេសក៍ណែនាំទូទៅ ដែលបានចេញដោយស្ថាប័នសន្ធិសញ្ញាជាច្រើន ដូចជាគណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិរបស់អង្គការសហប្រជាជាតិ

---

12 [12] International law defines discrimination as any distinction, exclusion, restriction or preference or other differential treatment that is directly or indirectly based on a prohibited ground of discrimination and that has the intention or effect of nullifying or impairing the recognition, enjoyment or exercise, on an equal footing, of rights guaranteed under international law. UNOHCHR, 'Born Free and Equal – Sexual orientation, gender identity and sex characteristics in International Human Rights Law' Secon Edition, 2019. Page 40. https://www.ohchr.org/Documents/Publications/BornFreeAndEqualLowRes.pdf

13 See Articles 2 and 7 of the Universal Declaration of Human Rights (UDHR). Articles 2(1) and 26 of the International Covenant on Civil and Political Rights(ICCPR). Article 2 of the International Covenant on Social Economic and Cultural Rights (ICESCR). Article 2 of the Convention on the Rights of the Child (CRC).

14 United Nations human rights treaty bodies are committees of independent experts which monitor implementation of the core international human rights treaties by State parties. UN treaty bodies perform country reviews (examines the situation in particular countries), prepares general comments (authoritative interpretations of particular rights or concepts in the Convention) and makes decisions on individual communications (complaints brought by individuals against states for violating the Covenant). More Information on UN Treaty Bodies: OHCHR, 'Human Rights Bodies' [webpage] https://www.ohchr.org/en/hrbodies/Pages/HumanRightsBodies.aspx#:~:text=Treaty%2Dbased%20bodies&text=Committee%20on%20Economic%2C%20Social%20and,Committee%20against%20Torture%20(CAT) ; ISHR video with explanation of UN Treaty Bodies https://www.youtube.com/watch?v=h2KV59JW318&list=PLdexkKNXSQRmug4rMq1lQSGjfYJPZ19ny&index=7 (ISHR video)

គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គណៈកម្មាធិការស្តីពីសិទ្ធិកុមារ និងគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងទៅលើស្ត្រីភេទ[15]។

- *"នេះមានន័យថា ការបែងចែកណាមួយទៅលើសិទ្ធិរបស់បុគ្គលដោយសារពួកគេជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ ឬ អ្នកប្តូរយេនឌ័រ គឺជាទង្វើខុសច្បាប់ ប្រៀបដូចនឹងការចាត់ទុកជាទង្វើខុសច្បាប់ សម្រាប់ការបែងចែកមនុស្សដោយផ្អែកទៅលើពណ៌សម្បុរ ពូជសាសន៍ ភេទ សាសនា និងស្ថានភាពផ្សេងទៀតដែរ។[16]"*

**គោលការណ៍យ៉កយ៉ាកាតា**

គោលការណ៍យ៉កយ៉ាកាតា ស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (ហៅកាត់ថាគោលការណ៍យ៉កយ៉ាកាតា) ផ្តល់នូវ**មគ្គុទេសក៍ណែនាំ ទាក់ទងទៅនឹងការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ចំពោះបញ្ហានានាជុំវិញនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ**[17]។ ទោះបីជាគោលការណ៍យ៉កយ៉ាកាតា មិនចងកាតព្វកិច្ចក៏ដោយ ក៏គោលការណ៍នេះ ត្រូវបានស្ថាប័នរបស់អង្គការសហប្រជាជាតិជាច្រើន ប្រើជាឯកសារយោង ដើម្បីជំរុញ និងបង្កើតច្បាប់ទាក់ទងនឹងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាដែរ[18]។

ព័ត៌មានបន្ថែម ស្តីពី**សិទ្ធិសូជីអេសស៊ី និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ៖**

- ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (OHCHR), "កើតមកដោយមានសេរីភាពនិងសមភាព-និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទ នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ" ការចេញផ្សាយលើកទី២ (២០១៩) https://www.ohchr.org/Documents/Publications/BornFreeAndEqualLowRes.pdf
- គេហទំព័រ UN Free and Equal៖ https://www.unfe.org/learn-more/

---

[15] UNOHCHR, "Born Free and Equal – Sexual orientation, gender identity and sex characteristics in International Human Rights Law", Second Edition, 2019. Pp 38-45 https://www.ohchr.org/Documents/Publications/BornFreeAndEqualLowRes.pdf
Committee on Economic, Social and Cultural Rights – See for instance: UN Economic and Social Council, 'General Comment No. 20 'Non-discrimination in economic, social and cultural rights (art. 2, para 2, of the International Covenant on Economic, Social and Cultural Rights)' (E/C.12/GC/20) (2009) Para 32 available at: http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=E%2FC.12%2FGC%2F20&Lang=en ;
United Nations Human Rights Committee - See for instance: UN Human Rights Committee, Toonen v Australia, Communication No 488/1992, 31 March 1994, CCPR/C/50/D/488/1992, para 8.7, available at: http://hrlibrary.umn.edu/undocs/html/vws488.htm. See also: CCPR/C/USA/CO/3, at para. 25.
Committee on the Elimination of Discrimination against Women - See for instance: CEDAW: General Recommendation No. 28 on the core obligations of States Parties under Article 2 of the Convention on the Elimination of All Forms of Discrimination against Women. (CEDAW/C/GC/28), 16 Dec. 2010, para. 18.
Committee on the Rights of the Child See for instance: United Nations (UN) Committee on the Rights of the Child (1989), "General Comment No. 4 'Adolescent Health and Development in the Context of the Convention on the Rights of the Child'", at para. 2; United Nations (UN) Committee on the Rights of the Child (1989), "General Comments No. 3 'HIV/AIDS and the Rights of the Child'", at para. 8; United Nations (UN) Committee on the Rights of the Child (1989), "General Comment No. 13 'The Right of the Child to Freedom from All Forms of Violence'", at paras. 60 and 72(g) (stressing that States parties must address discrimination against vulnerable or marginalized groups of children, including children who are lesbian, gay, transgender or transsexual)"; United Nations (UN) Committee on the Rights of the Child (CRC) (1989), "General Comment No. 15 (2013) on the right of the child to the enjoyment of the highest attainable standard of health", Article 24, para. 8.

[16] UN Free and Equal Factsheet on International Human Rights Law and Sexual Orientation & Gender Identity. https://www.unfe.org/wp-content/uploads/2018/10/International-Human-Rights-Law-English.pdf

[17] International Commission of Jurists (March 2007), "Yogyakarta Principles on the Application of International Human Rights Law in relation to Sexual Orientation and Gender Identity", http://yogyakartaprinciples.org/wp-content/uploads/2016/08/principles_en.pdf.
The Yogyakarta Principles, are a set of guidelines drafted by international human rights experts in 2006.
They were complemented in 2017 by the "Yogyakarta Principles plus 10". http://yogyakartaprinciples.org/wp-content/uploads/2017/11/A5_yogyakartaWEB-2.pdf

[18] Paula L Ettelbrick and Alia Trabucco Zerán, "The Impact of the Yogyakarta Principles on International Human Rights Law Development: A study of November 2007-June 2010" (2010), pp. 13-24. https://apf-prod.s3.amazonaws.com/media/resource_file/Yogyakarta_Principles_Impact_Human_Rights_Law.pdf?AWSAccessKeyId=AKIA57J6V557ISASX34R&Signature=pPUzPd2b8GBs9stBhckJNYMyypA%3D&Expires=1643083643

- សលាកបត្រ UN Free and Equal៖
  - សំណួរញឹកញាប់អំពីសមភាពនៃការស្រឡាញ់ភេទដូចគ្នា៖ https://www.unfe.org/wp-content/uploads/2018/10/FAQs-English.pdf
  - ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ៖ https://www.unfe.org/wp-content/uploads/2018/10/International-Human-Rights-Law-English.pdf

## 1.3 ទិដ្ឋភាពទូទៅ នៃស្ថានភាពសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងប្រទេសកម្ពុជា

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានការរីកចម្រើនគួរឲ្យកត់សម្គាល់មួយចំនួនក្នុងការលើកកម្ពស់ការយល់ដឹង និងការទទួលយកជាសាធារណៈចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។ សេចក្តីថ្លែងការណ៍ដោយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកទឹកចិត្តសាធារណជន ឲ្យបញ្ឈប់ការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងការងារលើកកម្ពស់ការយល់ដឹងដែលអនុវត្តដោយអង្គការសង្គមស៊ីវិល និងសកម្មជនតាមសហគមន៍នានា បានរួមចំណែកមួយផ្នែក ដល់ការធ្វើឲ្យប្រសើរឡើងនូវការលើកកម្ពស់ការយល់ដឹង និងការទទួលយកពីសាធារណជន[19]។ ខណៈពេលដែលមានវឌ្ឍនភាពគួរឲ្យកោតសរសើរនោះ អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ក៏នៅបន្តប្រឈមមុខនឹងការរើសអើងផ្នែកច្បាប់ និងផ្នែកសង្គម ក្នុងទម្រង់ផ្សេងៗនៅឡើយ ដោយសារតែនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ របស់ពួកគេ ដោយរួមបញ្ចូលទាំងការមិនអាចទទួលបាននូវសមភាពច្បាប់អាពាហ៍ពិពាហ៍ អំពើហិង្សានិងការបដិសេធពីក្រុមគ្រួសារ ការរើសអើងនិងការសម្លុតក្នុងបរិបទអប់រំ ការរើសអើងក្នុងបរិបទការងារ ឧបសគ្គក្នុងការទទួលបានសេវាថែទាំសុខភាពគ្រប់គ្រាន់ ការមិនអាចទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកប្តូរយេនឌ័រ[20] និងអំពើហិង្សាផ្អែកលើយេនឌ័រ[21]។

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាសិទ្ធិស្មើភាពគ្នាចំពោះប្រជាជនកម្ពុជាគ្រប់រូប ដោយឥតប្រកាន់អំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ និងធានាការគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំង កតិកាសញ្ញាអន្តរជាតិផ្សេងៗទៀត ទាក់ទងនឹងសិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ដោយរួមបញ្ចូលទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ កតិកាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង

[19] Joint Statement by Civil Society Organizations: Step Up Efforts To Protect The Rights Of Lesbian, Gay, Bisexual, Transgender, Intersex, Queer (LGBTIQ) People In Cambodia, In Line With The Universal Periodic Review Recommendations Accepted By Cambodia. (27 September 2021) https://rockcambodia.org/joint-statement-upr-mtr-2021/.

[20] Legal gender recognition refers to laws, policies or administrative procedures and processes which allow transgender and gender-diverse persons to have their self-defined gender-identity (gender markers and/or names) recognized on official identity documents.

[21] See in particular: Civil Society UPR Joint Submission: ‘Joint Submission to the UN Human Rights Council for the Third Universal Periodic Review of the Kingdom of Cambodia. SOGIESC & SRHR  in Cambodia’, (2018) available at https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf. ILGA Asia, Rainbow in the rain: the LGBTI community in Cambodia in the pursuit of freedom and equality (2021), https://www.ilgaasia.org/publications/cambodia-lgbtiq-rights-report-2021. See also detailed research reports presented in the table below.

វប្បធម៌[22]។ ក្របខ័ណ្ឌច្បាប់នៃប្រទេសកម្ពុជា មិនមានផ្តន្ទាទោសលើទំនាក់ទំនងភេទដូចគ្នានោះទេ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ ក៏ពុំទាន់មានការការពារផ្លូវច្បាប់យ៉ាងច្បាស់ប្រឆាំងនឹងការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅឡើយដែរ។ ក្រោមប្រព័ន្ធច្បាប់នាពេលបច្ចុប្បន្ននេះ ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានផាត់ចេញពីលទ្ធភាពដែលអាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ និងពីការទទួលបានការទទួលស្គាល់ផ្លូវច្បាប់ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ខ្លួន។ បន្ថែមពីលើនេះទៀត ពុំទាន់មានច្បាប់ ឬគោលនយោបាយណាដែលអនុញ្ញាតឲ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ សម្រាប់អ្នកប្តូរយេនឌ័រនៅឡើយ[23]។

ការសិក្សាស្រាវជ្រាវដែលមានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ពិភាក្សាលម្អិតអំពីស្ថានភាពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងសិទ្ធិសូជីអេសស៊ី នៅក្នុងប្រទេសកម្ពុជា។

### ប្រភពឯកសារបន្ថែមស្តីអំពីស្ថានភាពសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) នៅកម្ពុជា

ទិដ្ឋភាពទូទៅនៃស្ថានភាពសូជីអេសស៊ី នៅកម្ពុជា៖

- របាយការណ៍ យូ.ភី.អ រួមគ្នារបស់អង្គការសង្គមស៊ីវិល៖ "របាយការណ៍រួមជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សម្រាប់ការពិនិត្យជាសកលតាមកាលកំណត់លើកទីបី លើព្រះរាជាណាចក្រកម្ពុជា៖ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅកម្ពុជា" (២០១៨) អាចរកបាន https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf. Factsheets based on this report can be found at: https://rockcambodia.org/cambodia-3rd-cycle-of-universal-periodic-review-upr-on-sogiesc-srhr/
- ILGA Asia, "ឥន្ទធនូនៅក្នុងភ្លៀង៖ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ក្នុងដំណើរស្វែងរកសេរីភាពនិងសមភាព" (២០២១) អាចរកបានតាម https://www.ilgaasia.org/publications/cambodia-lgbtiq-rights-report-2021.
- UNDP & USAID, "ក្នុងនាមជាអ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី៖ របាយការណ៍ប្រចាំប្រទេសកម្ពុជា" (២០១៤) អាចរកបានតាម៖ https://www.refworld.org/docid/54ed86304.html.

ទិដ្ឋភាពជាក់លាក់មួយចំនួនស្តីអំពីស្ថានភាពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងសិទ្ធិសូជីអេសស៊ី ក្នុងប្រទេសកម្ពុជា អាចរកបាននៅក្នុងការបោះពុម្ពផ្សាយដូចខាងក្រោម៖

សិទ្ធិរៀបអាពាហ៍ពិពាហ៍ សុំកូន និងសិទ្ធិទទួលស្គាល់យេនឌ័រ សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា៖

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "គ្រួសារឥន្ទធនូនៅកម្ពុជា៖ សិទ្ធិរៀបអាពាហ៍ពិពាហ៍ សុំកូន និងការទទួលស្គាល់យេនឌ័រ ក្នុងព្រះរាជាណាចក្រកម្ពុជា" (២០១៧) អាចរកបានតាម៖

[22] Constitution of the Kingdom Cambodia (1993).

[23] Civil Society UPR Joint Submission: 'Joint Submission to the UN Human Rights Council for the Third Universal Periodic Review of the Kingdom of Cambodia. SOGIESC & SRHR in Cambodia', (2018) available at https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf. ILGA Asia, Rainbow in the rain: the LGBTI community in Cambodia in the pursuit of freedom and equality (2021), https://www.ilgaasia.org/publications/cambodia-lgbtiq-rights-report-2021.

https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=126&id=5&lang=khm (ភាសាខ្មែរ)
http://cchrcambodia.org/admin/media/report/report/english/2017-11-22-CCHR-Report-Cambodia-Rainbow-Families_ENG.pdf (ភាសាអង់គ្លេស)

អំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស៖

- អង្គការរ៉ក់ "របាយការណ៍អំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរ ភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងកម្ពុជា" (២០១៩) អាចរកបានតាម https://rockcambodia.org/i-married-a-man-to-satisfy-my-parents-2019/

សិទ្ធិមិនត្រូវបានរើសអើង ផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងវិស័យការងារ៖

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សិទ្ធិមិនត្រូវបានរើសអើង ដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ ក្នុងវិស័យការងារ នៅប្រទេសកម្ពុជា" (២០១៩) អាចរកបានតាម
https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=139&id=5&lang=khm (ភាសាខ្មែរ)
https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=139&id=5 (ភាសាអង់គ្លេស)

បរិយាប័ន្នផ្នែកសេដ្ឋកិច្ចសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា៖

- APCOM & Micro Rainbow International Foundation Cambodia, "ការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា" (២០២០) អាចរកបានតាម
https://www.apcom.org/wp-content/uploads/2020/12/2020-11-12_Report_APCOM_FinanceInc_Cambodia-withLogos.pdf

ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងវិស័យអប់រំ៖

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" (២០១៥) អាចរកបានតាម
https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=110&id=5&lang=khm (ភាសាខ្មែរ)
https://cchrcambodia.org/admin/media/report/report/english/2015_12_17_CCHR_REPORT_LGBT_Bullying_in_Cam_School_(ENG).pdf (ភាសាអង់គ្លេស)

ការទទួលបានសេវាសុខភាពគ្រប់ជ្រុងជ្រោយសម្រាប់អ្នកប្តូរយេនឌ័រ៖

- RoCK & Dr. Vic Salas, "Report Findings and Recommendations, Feasibility Study for a Transgender Project", January 2018, available at: https://www.rockcambodia.org/wp-content/uploads/2020/05/Findings_and_Recommendations-on-LGBT-health.pdf

ការរើសអើងលើអ្នកប្តូរភេទជាស្ត្រី៖

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុង

ព្រះរាជាណាចក្រកម្ពុជា" (២០១៦) អាចរកបានតាម https://cchrcambodia.org/admin/media/report/report/khmer/2016_09_21_SOGI_Report_Khm.pdf (ភាសាខ្មែរ) https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=115&id=3 (ភាសាអង់គ្លេស)

ឥរិយាបទនិងអាកប្បកិរិយារបស់សាធារណជន ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា៖

- RoCK & TNS "Research Report on Opinions, Attitudes, and Behavior toward the LGBT Population in Cambodia", (2015) https://www.rockcambodia.org/wp-content/uploads/2020/07/TNS-Research-Report-on-Opinions-Attitudes-and-Behavior-toward-the-LGBT-Population-in-Cambodia.pdf

ទិដ្ឋភាពទូទៅនៃសិទ្ធិមនុស្សសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា៖

- អង្គការរ៉ក់ & អង្គការគោលដៅយុត្តិធម៌ "មគ្គុទេសក៍ស្តីពីសិទ្ធិមនុស្សសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា" (២០១៥) អាចរកបានតាម https://rockcambodia.org/guide-to-human-rights-for-lgbt-in-cambodia/

ការទទួលបានជំនួយផ្នែកច្បាប់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា៖

- Destination Justice "Access to Legal Aid services by the LGBTIQ community in Cambodia" (2019)

https://destinationjustice.org/wp-content/uploads/2019/03/Final-EN-Report-Rainbow-Legal-Aid.pdf

## 2. ទិដ្ឋភាពទូទៅ នៃយន្តការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ)

- ការពិនិត្យជាសកលតាមការកំណត់ (យូ.ភី.អ) គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិ ដែលរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ពិនិត្យលើការអនុវត្តកាតព្វកិច្ចសិទ្ធិ មនុស្សរបស់រដ្ឋជាសមាជិកផ្សេងទៀត[24]។ គោលបំណងរបស់ យូ.ភី.អ រួមមាន៖
  - → ការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋសមាជិកនីមួយៗ
  - → ការបំពេញកាតព្វកិច្ចសិទ្ធិមនុស្ស និងការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់រដ្ឋនិមួយៗ ព្រមទាំងការវាយតម្លៃទៅលើការវិវឌ្ឍន៍វិជ្ជមាន និងបញ្ហាប្រឈមនានាដែលរដ្ឋសមាជិកជួបប្រទះ[25]
- ក្នុងអំឡុងពេលធ្វើកិច្ចសន្ទនាបែបអន្តរកម្មរបស់យន្តការ យូ.ភី.អ រដ្ឋសមាជិកដែលស្ថិតនៅក្រោមការត្រួតពិនិត្យនេះ ពន្យល់អំពីវិធានការនានា ដែលរដ្ឋនោះបានចាត់ឡើងក្នុងការគោរពសិទ្ធិមនុស្ស។ បន្ទាប់មក រដ្ឋជាសមាជិកផ្សេងទៀត (រដ្ឋផ្តល់អនុសាសន៍) ផ្តល់**អនុសាសន៍** អំពីរបៀបដែលរដ្ឋស្ថិតនៅក្រោមការពិនិត្យនោះ អាចយកទៅកែលម្អស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសរបស់ខ្លួន។

---

[24] Human Rights Council, Resolution 5/1, A/HRC/RES/5/1 (June 2007).

[25] Human Rights Council, Resolution 5/1, A/HRC/RES/5/1 (2007). "The objectives of the review are: (a)The improvement of the human rights situation on the ground; (b) The fulfilment of the State's human rights obligations and commitments and assessment of positive developments and challenges faced by the State".

▶ ដំណើរការនេះ ធ្វើឡើងសម្រាប់ប្រទេសនីមួយៗ រៀងរាល់ប្រាំ (៥) ឆ្នាំម្តង ដោយផ្អែកទៅលើមូលដ្ឋាននៃការវិលជុំ។




**លក្ខណៈពិសេសជាក់លាក់មួយចំនួនអំពី យូ.ភី.អ ក្នុងនាមជាយន្តការសម្រាប់ការពារសិទ្ធិមនុស្ស៖**

- យន្តការ យូ.ភី.អធ្វើការពិនិត្យទៅលើស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋទាំងអស់ដែលជាសមាជិកអង្គការសហប្រជាជាតិ ដោយយន្តការនេះមានគោលបំណង "ធានាឲ្យមានការគ្របដណ្តប់ជាសកល និងការប្រព្រឹត្តដោយស្មើភាពគ្នាទៅលើរដ្ឋទាំងអស់[26]"
- យន្តការយូ.ភី.អ វាយតម្លៃទៅលើអនុលោមភាពរបស់រដ្ឋនិមួយៗ ទៅនឹង**កាតព្វកិច្ចសិទ្ធិមនុស្សទាំងអស់** ព្រមទាំងលើកឡើងរាល់**បញ្ហាសិទ្ធិមនុស្សទាំងអស់** ដោយរួមបញ្ចូលទាំងសិទ្ធិទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី)[27]។
- យន្តការយូ.ភី.អ មានគោលបំណងជាយន្តការមួយដែលមានលក្ខណៈសហការគ្នា[28] ជាមួយដំណើរការរដ្ឋធ្វើការត្រួតពិនិត្យទៅលើរដ្ឋដទៃបែបស្លាបនានិងអន្តរកម្ម ទៅលើបញ្ហាសិទ្ធិមនុស្ស។
- យន្តការយូ.ភី.អ ផ្តល់នូវការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងដំណើរការត្រួតពិនិត្យនេះ ដោយរួមបញ្ចូលទាំង អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិផងដែរ[29]។

---

[26] Human Rights Council, Resolution 5/1, A/HRC/RES/5/1 (June 2007). Para 3(c)

[27] A/HRC/RES/5/1 para 3(a) Promote the universality, interdependence, indivisibility and interrelatedness of all human rights

[28] A/HRC/RES/5/1 para 3(b)

ការពិនិត្យជាសកលតាមកាលកំណត់(យូ.ភី.អ) ផ្អែកទៅលើឯកសារសំខាន់ៗចំនួនបី៖

- ▶ **របាយការណ៍ជាតិ៖** ព័ត៌មានដែលរៀបចំឡើងដោយរដ្ឋស្ថិតនៅក្រោមការពិនិត្យ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស និងពន្យល់អំពីវិធានការដែលបានចាត់ឡើងក្នុងការគោរពសិទ្ធិមនុស្ស[30]
- ▶ **ការចងក្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ៖** ការប្រមូលចងក្រងព័ត៌មានដែលមាននៅក្នុងរបាយការណ៍ស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស រួមបញ្ចូលទាំងការសង្កេតនិងមតិយោបល់ដោយរដ្ឋដែលបង្ហាញការព្រួយបារម្ភ ព្រមទាំងឯកសារផ្លូវការពាក់ព័ន្ធផ្សេងទៀតរបស់អង្គការសហប្រជាជាតិ[31]។
- ▶ **សេចក្តីសង្ខេបព័ត៌មានរបស់ភាគីពាក់ព័ន្ធ៖** ការប្រមូលចងក្រងព័ត៌មានដែលផ្តល់ដោយភាគីពាក់ព័ន្ធផ្សេងទៀត ដែលដាក់ជូនដល់យន្តការយូ.ភី.អ ដោយរួមបញ្ចូលទាំង**អង្គការមិនមែនរដ្ឋាភិបាល** និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិដែរ[32]។

### កញ្ចប់ឧបករណ៍សម្រាប់ សង្គមស៊ីវិល ក្នុងការចូលរួមជាមួយយន្តការណ៍យូ.ភី.អ ៖

- UPR Info, "ឯកសារចងក្រងសម្រាប់អង្គការសង្គមស៊ីវិល មគ្គុទ្ទេសក៍ទូលំទូលាយមួយសម្រាប់អង្គការសង្គមស៊ីវិល ក្នុងការចូលរួមជាមួយដំណើរការ យូ.ភី.អ" (២០១៧) https://www.upr-info.org/sites/default/files/general-document/pdf/upr_info_cso_compendium_en.pdf
- ILGA World, "ឧបករណ៍តស៊ូមតិក្នុងយន្តការ យូ.ភី.អ សម្រាប់និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ៖ មគ្គុទេសក៍សម្រាប់អ្នកការពារសិទ្ធិដែលធ្វើការទៅលើ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ" (២០១៧) https://ilga.org/downloads/SOGIESC_UPR_Advocacy_Toolkit.pdf

### ឯកសារបន្ថែមទៀតស្តីពីយន្តការ យូ.ភី.អ

- Miloon Kothari, "ការសិក្សាអំពីការអនុវត្តល្អថ្មីៗ ពីការពិនិត្យជាសកលតាមកាលកំណត់(យូ.ភី.អ)" (២០២១) https://www.upr-info.org/sites/default/files/general-document/pdf/emerging_upr_goodpractices.pdf
  - *"ការសិក្សាដែលផ្តោតជាចម្បងទៅលើទិដ្ឋភាពស្ថាប័ន ទិដ្ឋភាពនៃការចូលរួម និងទិដ្ឋភាពនីតិវិធីនេះ បង្ហាញថាផលប្រយោជន៍រយៈពេលវែងនៃការចូលរួមរបស់តួអង្គថ្នាក់ជាតិទាំងអស់ជាមួយដំណើរការយូ.ភី.អ នេះ គឺជាការបង្កើនតម្លាភាពទៅលើអនុលោមភាពរបស់រដ្ឋទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន និងការបង្កើននូវឱកាសក្នុងការរៀនសូត្រ និងការចូលរួមយ៉ាងសកម្មជាមួយប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដោយមានគោលបំណងធ្វើឲ្យកាន់តែប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស នៅក្នុងការអនុវត្តជាក់ស្តែង និងដើម្បី*

---

[29] A/HRC/RES/5/1 para 3(m)

[30] A/HRC/RES/5/1. Para 15(a)

[31] This compilation of UN information is prepared by the Office of the High Commissioner for Human Rights (OHCHR). A/HRC/RES/5/1. Para 15(b).

[32] A/HRC/RES/5/1. Para 15(c).The Office of the High Commissioner for Human Rights prepares a summary of such information.

*សម្រេចបាននូវសិទ្ធិរបស់មនុស្សទាំងអស់នៅក្នុងសង្គម ដោយចាប់ផ្តើមជាមួយនឹងក្រុមដែលងាយរងគ្រោះ ដែលត្រូវបានគេផាត់ចេញ និងដែលត្រូវបានគេរើសអើងបំផុត។"*

- J. Gomez and R. Ramcharan, "ការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) នៅអាស៊ីអាគ្នេយ៍៖ ទស្សនៈរបស់អង្គការសង្គមស៊ីវិល" (២០១៨) https://asiacentre.org/the-universal-periodic-review-of-southeast-asia-civil-society-perspectives/

## 3. យូ.ភី.អ សម្រាប់ប្រទេសកម្ពុជា៖ ការវិភាគសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ព្រមទាំងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ

យូ.ភី.អ វាយតម្លៃទៅលើអនុលោមភាពរបស់រដ្ឋ ទៅនឹងកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សទាំងអស់របស់ខ្លួន និងលើកឡើងនូវបញ្ហាសិទ្ធិមនុស្សជាច្រើន។ ឧទាហរណ៍ អនុសាសន៍យូ.ភី.អ ដែលប្រទេសកម្ពុជាបានទទួលនៅក្នុងវដ្តទីបីនោះ ផ្តោតទៅលើបញ្ហាសិទ្ធិមនុស្សជាច្រើន រួមបញ្ចូលទាំងសិទ្ធិស្ត្រី សេរីភាពសារព័ត៌មាន សិទ្ធិដីធ្លី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការការពារអ្នកការពារសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិជនមានពិការភាព សិទ្ធិជនជាតិដើមភាគតិច និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ។ ទោះបីជា យូ.ភី.អ ពិនិត្យទៅលើបញ្ហាសិទ្ធិមនុស្សជាច្រើនក៏ដោយ ក៏សលាកប័ត្រព័ត៌មាននេះ ផ្តោតជាក់លាក់ជាពិសេស ទៅលើរបៀបដែលសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ត្រូវបានលើកឡើងនៅក្នុង យូ.ភី.អ របស់ប្រទេសកម្ពុជា។

ប្រទេសកម្ពុជាបានឆ្លងកាត់ការពិនិត្យ ក្នុងដំណើរការ យូ.ភី.អ នេះ បានចំនួនបីជុំរួចមកហើយ៖

- ការពិនិត្យ យូ.ភី.អ ជុំទីមួយ សម្រាប់ប្រទេសកម្ពុជា (២០០៩)
- ការពិនិត្យ យូ.ភី.អ ជុំទីពីរ សម្រាប់ប្រទេសកម្ពុជា (២០១៤)
- ការពិនិត្យ យូ.ភី.អ ជុំទីបី សម្រាប់ប្រទេសកម្ពុជា (២០១៩)

**ព័ត៌មានបន្ថែមស្តីអំពី យូ.ភី.អ និងប្រទេសកម្ពុជា៖**

ក្រាហ្វិចព័ត៌មាន ដែលមានប្រយោជន៍ស្តីអំពី យូ.ភី.អ សម្រាប់ប្រទេសកម្ពុជា៖

https://www.sithi.org/km/upr

គេហទំព័រ OHCHR page UPR Cambodia:

https://www.ohchr.org/EN/HRBodies/UPR/Pages/KHindex.aspx

### 3.1 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ យូ.ភី.អ ជុំទីមួយ សម្រាប់ប្រទេសកម្ពុជា (២០០៩)

**យូ.ភី.អ ជុំទី១ សម្រាប់ប្រទេសកម្ពុជា**

- ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩៖ ការពិនិត្យឡើងវិញនៅក្នុងក្រុមការងារ យូ.ភី.អ

- អនុសាសន៍សរុបចំនួន ១៣៨ បានទទួលពីប្រទេសចំនួន ៤៧
  - ទទួលយក៖ ១៣៨ ទៅលើបញ្ហាសិទ្ធិមនុស្សជាច្រើន
  - មិនគាំទ្រ៖ គ្មាន

### បញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងអំឡុងការពិនិត្យ ជុំទី១ សម្រាប់ប្រទេសកម្ពុជា

- ការដាក់របាយការណ៍របស់ភាគីពាក់ព័ន្ធ (ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិល)៖
  - មានការដាក់របាយការណ៍របស់ភាគីពាក់ព័ន្ធសរុបចំនួន ២៣ ដែលផ្តោតលើបញ្ហាសិទ្ធិមនុស្សជាច្រើន[33] ប៉ុន្តែ **មិនមានការលើកឡើងដោយផ្ទាល់អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី)**ទេ[34]
- របាយការណ៍ថ្នាក់ជាតិ៖ មិនមានការលើកឡើងអំពីសិទ្ធិសូជីអេសស៊ី ទេ[35]
- កម្រងព័ត៌មានអង្គការសហប្រជាជាតិ៖ មិនមានការលើកឡើងអំពីសិទ្ធិសូជីអេសស៊ី ទេ[36]
- ការពិភាក្សារបស់ក្រុមការងារ៖ មិនមានការលើកឡើងអំពីសិទ្ធិសូជីអេសស៊ី ទេ[37]
- អនុសាសន៍៖ មិនមានការលើកឡើងអំពីសិទ្ធិសូជីអេសស៊ី ទេ[38]

### យូ.ភី.អ ជុំទីមួយ និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក

➔ អនុសាសន៍ចំនួន **៥០២** ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទនៅទូទាំងសកលលោក ត្រូវបានដាក់ដោយប្រទេសចំនួន **៣៥** ជូនដល់ប្រទេសចំនួន **១៣៥**[39]

## 3.2 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ យូ.ភី.អ ជុំទីពីរ សម្រាប់ប្រទេសកម្ពុជា (២០១៤)

### យូ.ភី.អ ជុំទី២ សម្រាប់ប្រទេសកម្ពុជា

- ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤៖ ការពិនិត្យឡើងវិញនៅក្នុងក្រុមការងារ យូ.ភី.អ
- អនុសាសន៍សរុបចំនួន ២០៥ បានទទួលពីប្រទេសចំនួន ៧៦

---

[33] Cambodia First Cycle UPR. Summary of stakeholders information https://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/A_HRC_WG6_6_KHM_3_E.pdf

[34] The compilation of stakeholders information does not refer to SOGIESC rights of LGBT+ people's rights. One of the joint submission (JS6) refers to sexual reproductive health and rights but with no direct reference to LGBTIQ+ people's rights. https://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/A_HRC_WG6_6_KHM_3_E.pdf

[35] Cambodia First Cycle UPR. National Report. https://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/A_HRC_WG6_6_KHM_1_E.pdf

[36] https://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/A_HRC_WG6_6_KHM_2_E.pdf

[37] https://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/A_HRC_13_4_KHM_E.pdf

[38] https://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/A_HRC_13_4_KHM_E.pdf

[39] Source: UPR Info Database on UPR recommendations. Online. [Accessed 19.12.2021] https://upr-info-database.uwazi.io/en/library/table/?q=(allAggregations:!f,filters:(cycle:(values:!(%273eec3a87-0825-4a8f-a37d-6ca7b03715e4%27)),issues:(values:!(%276e415998-2b91-42a8-94a5-a21859de6cdd%27))),from:90,includeUnpublished:!f,limit:30,order:desc,sort:creationDate,types:!(%275d8ce04361cde0408222e9a8%27),unpublished:!f)

- ទទួលយក៖ ១៦៣ ទៅលើបញ្ហាសិទ្ធិមនុស្សជាច្រើន
- មិនគាំទ្រ៖ កត់សម្គាល់ចំនួន ៣៨ និង "បដិសេធ" ចំនួន ៤ [40]

### បញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងអំឡុងការពិនិត្យ ជុំទី២ សម្រាប់ប្រទេសកម្ពុជា

- ការដាក់របាយការណ៍របស់ភាគីពាក់ព័ន្ធ (ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិល)៖
  - មានការដាក់របាយការណ៍របស់ភាគីពាក់ព័ន្ធសរុបចំនួន ៣៧ ដែលផ្តោតលើបញ្ហាសិទ្ធិមនុស្សជាច្រើន[41] ដោយមាន**អង្គការសង្គមស៊ីវិលចំនួន២ ផ្តោតទៅលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា**[42]
- របាយការណ៍ថ្នាក់ជាតិ៖ មិនមានការលើកឡើងអំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ទេ[43]
- ព័ត៌មានអង្គការសហប្រជាជាតិ៖ មិនមានការលើកឡើងអំពីសិទ្ធិសូជីអេសស៊ី ទេ[44]
- ការពិភាក្សារបស់ក្រុមការងារ៖ មិនមានការលើកឡើងអំពីសិទ្ធិសូជីអេសស៊ី ទេ
- អនុសាសន៍៖
  - **មិនមានការលើកឡើងដោយផ្ទាល់អំពីសិទ្ធិសូជីអេសស៊ី ទេ**
  - អនុសាសន៍ទូទៅមួយចំនួនស្តីពីសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ស្តីពីការលុបបំបាត់ការរើសអើងទៅលើស្ត្រី និងសិទ្ធិទទួលបានសុខភាពរបស់ក្រុមងាយរងគ្រោះ ទោះបីជាមិនបានយោងដោយផ្ទាល់ទៅលើសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានិងសិទ្ធិសូជីអេសស៊ី ក៏ដោយ[45]

### យូ.ភី.អ ជុំទីពីរ និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក

➔ អនុសាសន៍ចំនួន **៩៥៨** ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក ត្រូវបានដាក់ដោយប្រទេសចំនួន **៥១** ជូនដល់ប្រទេសចំនួន **១៥៨**[46]

## 3.3 សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ យូ.ភី.អ ជុំទីបីសម្រាប់ប្រទេសកម្ពុជា (២០១៩)

---

[40] https://documents-dds-ny.un.org/doc/UNDOC/GEN/G14/066/09/PDF/G1406609.pdf?OpenElement
[41] Summary of stakeholders information https://documents-dds-ny.un.org/doc/UNDOC/GEN/G13/184/24/PDF/G1318424.pdf?OpenElement .
[42] JS 14 by Rainbow Community Kampuchea (RoCK), Cambodian People Living with HIV/AIDS Network (CPN), Women Network for Unity (WNU), Community Legal Service (CLS) and CamASEAN's Youth Future (CamASEAN). See: Summary of stakeholders information https://documents-dds-ny.un.org/doc/UNDOC/GEN/G13/184/24/PDF/G1318424.pdf?OpenElement. JS 14 can be downloaded via: https://www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS18.aspx .
JS 16 by Cambodian Center for Human Rights (CCHR), Asia-Pacific Network of People Living with HIV/AIDS (APN+) and Sexual Rights Initiative (SRI). See: Summary of stakeholders information https://documents-dds-ny.un.org/doc/UNDOC/GEN/G13/184/24/PDF/G1318424.pdf?OpenElement. JS 16 can be downloaded via:
https://www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS18.aspx .
[43] https://documents-dds-ny.un.org/doc/UNDOC/GEN/G13/187/29/PDF/G1318729.pdf?OpenElement
[44] https://documents-dds-ny.un.org/doc/UNDOC/GEN/G13/184/59/PDF/G1318459.pdf?OpenElement
[45] https://documents-dds-ny.un.org/doc/UNDOC/GEN/G14/127/27/PDF/G1412727.pdf?OpenElement
[46] Source = UPR Info Database on UPR recommendations. Online. Accessed 19.12.2021. https://upr-info-database.uwazi.io/en/library/?q=(allAggregations:!f,filters:(cycle:(values:!(b237423c-6c85-4329-b3b0-acd1ceae04ed)),issues:(values:!(%276e415998-2b91-42a8-94a5-a21859de6cdd%27))),from:0,includeUnpublished:!f,limit:30,order:desc,sort:creationDate,types:!(%275d8ce04361cde0408222e9a8%27),unpublished:!f)

## យូ.ភី.អ ជុំទី៣ សម្រាប់ប្រទេសកម្ពុជា

- ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩៖ ការពិនិត្យឡើងវិញនៅក្នុងក្រុមការងារ យូ.ភី.អ
- អនុសាសន៍សរុបចំនួន ១៩៨ បានទទួលពីប្រទេសចំនួន ៧៣[47]
  - ទទួលយក៖ ១៧៣ ទៅលើបញ្ហាសិទ្ធិមនុស្សជាច្រើន[48]
  - មិនគាំទ្រ៖ ២៥

វីដេអូស្តីពីការត្រួតពិនិត្យទៅលើប្រទេសកម្ពុជាថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ដោយក្រុមការងារ ស្តីពី យូ.ភី.អ អាចរកបានតាម៖ https://sithi.org/upr/universal-periodic-review-third-cycle-cambodia.

## បញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ក្នុងអំឡុងការពិនិត្យ ជុំទី៣ សម្រាប់ប្រទេសកម្ពុជា

- ការដាក់របាយការណ៍របស់ភាគីពាក់ព័ន្ធ (ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិល)[49]៖
  - មានការដាក់របាយការណ៍របស់ភាគីពាក់ព័ន្ធសរុបចំនួន ៣១ ដែលបានដាក់អំពីបញ្ហាសិទ្ធិមនុស្សជាច្រើន ដោយរួមបញ្ចូលទាំង[50]៖
    - ការដាក់របាយការណ៍របស់អង្គការសង្គមស៊ីវិលចំនួន១ ផ្តោតទៅលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី)
      - "ការដាក់បាយការណ៍រួមគ្នា ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ យូ.ភី.អ ជុំទីបី សម្រាប់ប្រទេសកម្ពុជា៖ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ក្នុងប្រទេសកម្ពុជា" អាចរកបានតាម https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf.[51]
    - សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ក៏ត្រូវបានលើកឡើងនៅក្នុងរបាយការណ៍អង្គការសង្គមស៊ីវិលចំនួន២ ផ្សេងទៀត ស្តីពីសិទ្ធិទទួលបានយុត្តិធម៌ និងស្តីពីសុខភាពសាធារណៈ[52]
- របាយការណ៍ថ្នាក់ជាតិ៖ មិនមានការលើកឡើងអំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ឬសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ទេ[53]

---

[47] Report of the working group https://documents-dds-ny.un.org/doc/UNDOC/GEN/G19/098/90/PDF/G1909890.pdf?OpenElement
5 July 2019 : Adoption in the Plenary
[48] Addendum 1 Views on conclusions and/or recommendations, voluntary commitments and replies presented by the State under review https://daccess-ods.un.org/tmp/7925950.88481903.html
[49] Summary of stakeholders information, para 12-13. https://documents-dds-ny.un.org/doc/UNDOC/GEN/G18/333/54/PDF/G1833354.pdf?OpenElement
[50] Including 17 joint-submissions and 14 individual submissions. Summary of stakeholders information. https://documents-dds-ny.un.org/doc/UNDOC/GEN/G18/333/54/PDF/G1833354.pdf?OpenElement
[51] CCHR, RoCK, Destination Justice, Micro Rainbow International, the Reproductive Health Association of Cambodia, the International Lesbian, Gay, Bisexual, Trans and Intersex Association, ILGA Asia, ASC, RFSU, ActionAid Cambodia, DCA, and CamASEAN, 'Joint Submission to the UN Human Rights Council for the Third Universal Periodic Review of the Kingdom of Cambodia. Sexual Orientation, Gender Identity and Expression and Sex Characteristics (SOGIESC) Rights and Sexual Reproductive Health and Rights (SRHR) in Cambodia', (12 July 2018), https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf.
[52] Joint-Submission on Access to Justice, by Cambodian Center for Human Rights ("CCHR"), Destination Justice ("DJ") and The Cambodian Human Rights and Development Association ("ADHOC"), and endorsed by Advocacy and Policy Institute ("API"), Transparency International Cambodia ("TIC"), and International Freedom of Expression Exchange ("IFEX"). Direct mention of LGBTIQ+ persons rights in Para 12 and 30.
Joint Submission on Public Health in Cambodia, by Social Action for Community and Development ("SADC"), Women's Network for Unity ("WNU"), Rainbow Community Kampuchea ("RoCK"), and Health Action Coordination Committee ("HACC"), in para Xiii and 25.
[53] https://documents-dds-ny.un.org/doc/UNDOC/GEN/G13/187/29/PDF/G1318729.pdf?OpenElement

- កម្រងព័ត៌មានអង្គការសហប្រជាជាតិ៖ បានបញ្ចូលសិទ្ធិសូជីអេសស៊ី[54]
- សំណួរដែលដាក់ជូនមុន៖ រដ្ឋចំនួន៤ បានលើកឡើងអំពីសិទ្ធិសូជីអេសស៊ី (ប្រទេសស៊ុយអែត សហរដ្ឋអាមេរិច ប្រទេសប៊ែលហ្សិក ប្រទេសអេស្ប៉ាញ) [55]
- ការពិភាក្សារបស់ក្រុមការងារយូ.ភី.អ៖ មានលើកឡើងអំពីសិទ្ធិសូជីអេសស៊ី៖
  - ប្រតិភូប្រទេសកម្ពុជា បានលើកឡើងអំពីវិធានការនានាដែលរដ្ឋាភិបាលបានចាត់ឡើង សំដៅលុបបំបាត់ការរើសអើងប្រឆាំងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា[56]
  - ក្នុងអំឡុងការពិនិត្យរបស់ក្រុមការងារនេះ រដ្ឋសមាជិកអង្គការសហប្រជាជាតិចំនួន៤ បានថ្លែងអំពីស្ថានភាពសិទ្ធិសូជីអេសស៊ី/សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា[57]
- អនុសាសន៍៖
  - **អនុសាសន៍ចំនួន ៩** ដាក់លាក់ទៅលើសិទ្ធិសូជីអេសស៊ី **ត្រូវបានផ្តល់ និងបានទទួលយក**[58] (សូមមើលតារាងខាងក្រោម)

---

[54] https://documents-dds-ny.un.org/doc/UNDOC/GEN/G13/184/59/PDF/G1318459.pdf?OpenElement

[55] Sweden: "Sweden acknowledges steps taken towards a new "life skills" curriculum for grades 5-12 offering inclusive education on sexual orientation, sexuality education and gender-based violence. When can this new important curriculum be introduced and how will the Kingdom of Cambodia ensure that all teachers receive comprehensive training on SRHR, including LGBTI-persons' full enjoyment of human rights?"

United States of America: "One nongovernmental organization reported more than 100 incidents of violence or abuse against LGBTI persons in Cambodia, including domestic violence by family members. What steps is the government taking to protect these persons from such violence?"

Belgium: "How is the government of Cambodia protecting LGBTI persons from stigma and discrimination? Does the government consider introducing specific anti-discrimination legislation?"

Spain: "What measures have been taken by the Government to effectively implement the existing laws in order to improve the integration of the LGBTI community into the society?"

https://www.ohchr.org/EN/HRBodies/UPR/Pages/KHindex.aspx

[56] The delegation of Cambodia Intervention made during the Working Group Review interactive dialogue, on 30 January 2019**:**

"82. Even though there was no policy or legal framework governing the rights of the lesbian, gay, bisexual and transgender community, the Government had taken action to eliminate discrimination against that community by organizing public awareness campaigns, disseminated via the media and in the context of formal and informal education. While civil law still did not recognize the legitimacy of homosexual marriage and registration, it did not actually criminalize such marriage and practices. Homosexual marriage was in fact very common in Cambodian society, in traditional and cultural practices. Approximately 1,000 same-sex couple had already married with a traditional party and ceremony." https://documents-dds-ny.un.org/doc/UNDOC/GEN/G19/098/90/PDF/G1909890.pdf?OpenElement

See also: video recording of the Working Group Session Third UPR of Cambodia, 30 January 2019, available at: https://sithi.org/upr/universal-periodic-review-third-cycle-cambodia - Full unofficial transcription of speech by Cambodia Delegation (1hour46minutes to 1hour50minutes of the video recording). Unofficial transcription by ILGA World https://ilga.org/downloads/32st_UPR_Working_Group_Session_SOGIESC_recommendations.pdf "Related to sexual orientation, sexuality education and gender based violence, the Royal Government has made significant effort to eliminate discrimination against women and to promote gender equality and equity in Cambodia through the development and implementation of legal framework, policy, action-plan and education program to address and respond to discrimination, violence against women and girls, to promote equality between men and women in the society. According to regulation strategy phase four the Government has clear plan to promote gender equality, sexual orientation, sexuality education, to eliminate discrimination and gender based violence as following; implement gender equality in policy framework and national development plan, reducing gender gap in education, vocational training and the civil service, widening women entrepreneurship initiative, reducing domestic violence and sexual abuse against women and children, uplifting social morality, women's dignity and Cambodian family, improving legal services for women and children, put in place and implement the social protection policy framework 2016 to 2025." "Related to LGBT, even though there is a lack of policy and legal framework governing the right of LGBT people, the Government has been taking some action eliminating discrimination against LGBT community in Cambodia through promoting the public awareness on this issue and the dissemination program via media, formal and informal communication. Regard with legal awareness the civil law of Cambodia not yet recognize the legitimacy of homosexual marriage and registration, however the law not either criminalize such marriage and practice like some other countries. Such homosexual marriage is okay and very common in Cambodian society through traditional and cultural practices, as is found that approximately one thousand same-sex couples have already been married with traditional party and ceremony. In reality the LGBT people in Cambodia are exercising their rights and freedom without restriction from the Government and are doing a lot of advocacy campaign locally and internationally to promote their rights and freedom with full support and participation from the Government, particularly the CHRC. And also Prime Minister sent a message to the LGBT community through CHRC President, that the Government must take the lead in promoting LGBT rights and eliminating all form of discrimination against this community in Cambodia. However, to amend the civil law in order to legalize such practice there need to be more advocacy and promotion of public awareness so that it is more acceptable from society and community, so the cultural resistance becomes less and as a result the law will then be amended accordingly."

**[57] Remarks of States during the review of the working group:**

- Greece: "We would like to note Cambodia's progress in respect of LGBTIQ inclusion, as well as the development of a safety net for the most vulnerable, including persons with disabilities."
- Latvia: "Latvia notes received visits from the Special Rapporteur on the situation of human rights in Cambodia and accepted visit requests by the Special Rapporteur on the rights of persons with disabilities and Independent Expert on protection against violence and discrimination based on sexual orientation and gender identity."
- Netherlands: "The Netherlands commends Cambodia for its commitment to inclusive instruction on sexual orientation issues, sexual education, gender based-violence for grades 5 to 12."
- Sweden: "Sweden welcomes Cambodia's participation in the UPR process and acknowledges steps towards a strengthening of LGBTI persons' full enjoyment of human rights."

https://documents-dds-ny.un.org/doc/UNDOC/GEN/G19/098/90/PDF/G1909890.pdf?OpenElement

| អនុសាសន៍ចំនួន៩ ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ដែលបានផ្តល់ និង<u>បានទទួលយក</u> ដោយប្រទេសកម្ពុជាក្នុងការត្រួតពិនិត្យ យូ.ភី.អ ជុំទី៣ | |
|---|---|
| **អនុសាសន៍** | **រដ្ឋផ្តល់អនុសាសន៍** |
| **ការអនុម័តច្បាប់ និងគោលនយោបាយដែលធានាមិនឲ្យមានការរើសអើងផ្អែកលើមូលដ្ឋាន និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ** | |
| បង្កើតច្បាប់ប្រឆាំងការរើសអើងដែលធានា និងចែងយ៉ាងច្បាស់នូវការហាមឃាត់រាល់ទម្រង់នៃការរើសអើងទាំងអស់ ដោយរួមបញ្ចូលទាំងការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ។ (១១០.៤៥) | អ៊ីស្លង់ |
| រៀបចំកិច្ចពិភាក្សាជាមួយសង្គមស៊ីវិល ទៅលើលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ គ្រប់ជ្រុងជ្រោយ ប្រឆាំងនឹងការរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ព្រមទាំងធានាឲ្យមានការអនុវត្តនៅគ្រប់ស្ថាប័នសាធារណៈទាំងអស់ ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងការងារ។ (១១០.៥០) | ម៉ិចស៊ីកូ |
| បង្កើតលិខិតបទដ្ឋានគតិយុត្ត ដែលធានាភាពស្មើគ្នា និងចែងយ៉ាងច្បាស់អំពីការហាមឃាត់ការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា។ (១១០.៥២) | ស៊ុយអែត |
| រៀបចំវិធានការដែលមានប្រសិទ្ធភាព ដើម្បីលុបចោល និងដាក់ទោសអំពើរើសអើង និងអំពើហិង្សាផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ។ (១១០.៥៣) | អ៊ុយរូហ្គាយ |
| ត្រឹមឆ្នាំ ២០២៣ បង្កើតច្បាប់ប្រឆាំងការរើសអើងដែលធានានូវសមភាព និងចែងយ៉ាងច្បាស់នូវការហាមឃាត់រាល់ទម្រង់នៃការរើសអើងទាំងអស់ រាប់បញ្ចូលទាំងការរើសអើងផ្អែកលើសាសនា និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និង លក្ខណៈភេទ។ (១១០.៥៤) | អូស្ត្រាលី |
| **សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា** | |
| វិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតិ សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា។ (១១០.៤៧) | អ៊ីស្លង់ |
| វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតិសមភាពច្បាប់អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យមានការអនុវត្តស្មើភាព និងពេញលេញចំពោះប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាលើគ្រប់វិស័យ។ (១១០.៥១) | ហូឡង់ |
| វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតសមភាពច្បាប់រៀបអាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា។ (១១០.៥៥) | កាណាដា |
| **ច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកផ្លាស់ប្តូរយេនឌ័រ** | |
| បង្កើតច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រសម្រាប់អ្នកផ្លាស់ប្តូរយេនឌ័រ។ (១១០.៥៤) | អ៊ីស្លង់ |

## យូ.ភី.អ ជុំទីបី និងសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅទូទាំងសកលលោក

[58] https://documents-dds-ny.un.org/doc/UNDOC/GEN/G19/098/90/PDF/G1909890.pdf?OpenElement https://documents-dds-ny.un.org/doc/UNDOC/GEN/G19/110/92/PDF/G1911092.pdf?OpenElement

➔ យូ.ភី.អជុំទីបី នៅមិនទាន់ចប់នៅឡើយ[59]។ ផ្អែកលើទិន្នន័យដែលអាចរកបានពីជុំទីបី រហូតមកដល់ពេលនេះ (ទិន្នន័យអាចរកបានរហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០) មានអនុសាសន៍ចំនួន **១១៩៨** ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ដែលបានដាក់ដោយប្រទេសចំនួន **៦៣** ជូនដល់ប្រទេសចំនួន **១៣៥** [60]

| ព័ត៌មានសង្ខេប ... សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) ក្នុងយន្តការ យូ.ភី.អ នៅទូទាំងសកលលោក | | | |
|---|---|---|---|
| **ជុំនៃ យូ.ភី.អ** | អនុសាសន៍ស្តីពីសិទ្ធិសូជីអេសស៊ី នៅទូទាំងសកលលោក | ផ្តល់ដោយ ... រដ្ឋដែលផ្តល់អនុសាសន៍ | ទៅកាន់ ... រដ្ឋស្ថិតក្រោមការពិនិត្យ |
| **ជុំទី១** ២០០៨-២០១២ | **៥០២** | ៣៥ | ១៣៥ |
| **ជុំទី២** ២០១២-២០១៦ | **៩៥៨** | ៥១ | ១៥៨ |
| **ជុំទី៣** ២០១៧-២០២១ | **១១៩៨*** | ៦៣* | ១៣៥* |

ការសិក្សាមួយស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅក្នុងវដ្ត យូ.ភី.អ ចំនួនពីរជុំបូង ដោយ ILGA, ARC International និង វិទ្យាស្ថានសិទ្ធិមនុស្សរបស់គណៈមេធាវីអន្តរជាតិ (IBAHRI) ក្នុងឆ្នាំ២០១៦ បានវិភាគអំពីតួនាទីរបស់ យូ.ភី.អ ក្នុងការសម្រួចការការពារសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងបានកត់សម្គាល់ថា៖ "ពីទស្សនៈរបស់អង្គការសង្គមស៊ីវិល យូ.ភី.អ គឺជាវេទិកាដ៏មានសារៈសំខាន់បំផុតមួយ ដើម្បីធ្វើឲ្យមើលឃើញច្បាស់ អំពីការរំលោភបំពានសិទ្ធិមនុស្សជាច្រើនរូបភាព ទៅលើអ្នកស្រឡាញ់ភេទដូចគ្នានៅជុំវិញពិភពលោក និងជាយន្តការដើម្បីឲ្យរដ្ឋសមាជិកមានគណនេយ្យភាពចំពោះបញ្ហានេះ។ អង្គការសង្គមស៊ីវិលបានទាមទារ នូវលំហសម្រាប់លើកឡើងបញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ តាមរយៈការដាក់របាយការណ៍ ការធ្វើបទអន្តរាគមន៍ផ្ទាល់មាត់ និងការតស៊ូមតិជាមួយរដ្ឋាភិបាល ស្ថានទូត និងបេសកកម្មនានា។"[61]

### 3.4 ផ្លូវឆ្ពោះទៅមុខសម្រាប់តួនាទីរបស់ យូ.ភី.អ ក្នុងការរួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅប្រទេសកម្ពុជា

#### 3.4.1 ដំណាក់កាលខាងមុខនៃដំណើរការ យូ.ភី.អ នៅកម្ពុជា

[59] https://www.ohchr.org/EN/HRBodies/UPR/Pages/CyclesUPR.aspx

[60] Source : UPR Info Database on UPR recommendations. Online. [Accessed 19.12.2021] https://upr-info-database.uwazi.io/en/library/table/?q=(allAggregations:!f,filters:(cycle:(values:!(%27567eec7b-d5ab-4c36-a712-57c38fae9124%27)),issues:(values:!(%276e415998-2b91-42a8-94a5-a21859de6cdd%27))),from:0,includeUnpublished:!f,limit:30,order:desc,sort:creationDate,types:!(%275d8ce04361cde0408222e9a8%27),unpublished:!f)

[61] International Lesbian, Gay, Bisexual, Trans and Intersex Association (ILGA), in collaboration with ARC International and the International Bar Association's Human Rights Institute (IBAHRI), *Sexual Orientation, Gender Identity and Expression, and Sex Characteristics at the Universal Periodic Review. (November 2016)* https://ilga.org/new-report-finds-upr-crucial-to-protect-human-rights-of-lgbti-persons-worldwide .

ដំណាក់កាលអនុវត្ត → ការរៀបចំសម្រាប់ការពិនិត្យនៅជុំបន្ទាប់ → ការពិនិត្យជាសកលតាមកាលកំណត់ជុំទី៤សម្រាប់កម្ពុជា

| | | |
|---|---|---|
| ខែមករា ឆ្នាំ២០២២៖ របាយការណ៍ដោយស្ម័គ្រចិត្ត ពាក់កណ្ដាលអាណត្តិ | របាយការណ៍អង្គការសង្គមស៊ីវិលសម្រាប់ យូ.ភី.អ កម្ពុជា ជុំបន្ទាប់ | យូ.ភី.អ ជុំបន្ទាប់សម្រាប់កម្ពុជា៖ ខែឧសភា ២០២៤ |

## ដំណាក់កាលអនុវត្ត និងចិរវេលាការរាយការណ៍ពាក់កណ្ដាលអាណត្តិ

- ពេលវេលាចន្លោះ យូ.ភី.អជុំទីបី សម្រាប់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ រហូតដល់យូ.ភី.អនៅជុំបន្ទាប់ដែលត្រូវបានកំណត់កាលបរិច្ឆេទក្នុងឆ្នាំ២០២៤ គឺជា**ដំណាក់កាលអនុវត្ត**យូ.ភី.អជុំទីបី របស់ប្រទេសកម្ពុជា ហើយដែលក្នុងអំឡុងពេលនេះ ប្រទេសកម្ពុជាគួរអនុវត្តឲ្យបានសម្រេច ទៅលើអនុសាសន៍ដែលបានទទួលយក។
- **ការរាយការណ៍ពាក់កណ្ដាលអាណត្តិតាមការស្ម័គ្រចិត្ត** គឺជាដំណើរការស្ម័គ្រចិត្តមួយដែលអនុញ្ញាតឲ្យរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ និងភាគីពាក់ព័ន្ធផ្សេងទៀត (រួមទាំងសង្គមស៊ីវិល) អាចផ្ដល់បច្ចុប្បន្នភាពពាក់កណ្ដាលអាណត្តិ ទៅលើតាមដានការអនុវត្ត នៃអនុសាសន៍ដែលប្រទេសកម្ពុជាបានទទួលយក[62]។ មិនមានកាលបរិច្ឆេទជាក់លាក់ណាមួយសម្រាប់ចិរវេលាដាក់របាយការណ៍ពាក់កណ្ដាលអាណត្តិដោយស្ម័គ្រចិត្តនេះទេ ប៉ុន្តែ ជាទូទៅ វាអាចនៅចន្លោះពាក់កណ្ដាលរវាងយូ.ភី.អនីមួយៗ ហើយសម្រាប់ប្រទេសកម្ពុជា ពាក់កណ្ដាលអាណត្តិ គឺអាចនៅចន្លោះចុងឆ្នាំ២០២១ ដល់ដើមឆ្នាំ២០២២។
- របាយការណ៍ពាក់កណ្ដាលអាណត្តិដោយស្ម័គ្រចិត្តនេះ បង្កើតបានជា "ប្រភពព័ត៌មានដ៏សំខាន់ស្ដីពីការរីកចម្រើនឬការខ្វះខាតការរីកចម្រើននានាទាក់ទងជាមួយនឹងការអនុវត្តអនុសាសន៍ ក្នុងអំឡុងពេល៥ឆ្នាំ នៅក្នុងចន្លោះរវាងការពិនិត្យមួយទៅការពិនិត្យមួយទៀត"[63]។
  - របាយការណ៍ពាក់កណ្ដាលអាណត្តិដោយស្ម័គ្រចិត្តនៃ យូ.ភី.អ សម្រាប់ប្រទេសកម្ពុជា ដែលអាចដាក់ជូនដោយភាគីពាក់ព័ន្ធ តាមគោលការណ៍ស្ម័គ្រចិត្តនេះ រួមបញ្ចូលទាំងរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ និងអង្គការសង្គមស៊ីវិល អាចរកបាននៅក្នុងគេហទំព័រ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដូចខាងក្រោម៖ https://www.ohchr.org/EN/HRBodies/UPR/Pages/UPRImplementation.aspx.
  - ទាក់ទងជាពិសេសលើ**សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ** អង្គការសង្គមស៊ីវិលធ្វើការលើការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅកម្ពុជា បានបោះផ្សាយនូវ

[62] In 2011, the Human Rights Council, while evaluating the UPR process five years after its creation, recognized the need for strengthened follow-up measures, and institutionalised mid-term reporting as a voluntary important component of the UPR process. States are encouraged to provide the Council, on a voluntary basis, with a midterm update on follow-up to accepted recommendations. (A/HRC/RES/16/21). UN Resolution A/RES/16/21, "Review of the work and functioning of the Human Rights Council" (12 April 2011). https://www.upr-info.org/sites/default/files/general-document/pdf/a_hrc_res_16_21_hrc_review_e.pdf

[63] For more information on UPR mid-term reporting, see: UPRInfo, "UPR Mid-term reporting: Optimizing sustainable implementation, Good practices for UPR stakeholders. (2018) https://www.upr-info.org/sites/default/files/general-document/pdf/upr_midterm_report_web_v1_high.pdf
See also : The Geneva Academy of International Humanitarian Law and Human Rights, "The Universal Periodic Review Mid-Term Reporting Process: Lessons For The Treaty Bodies" (2019): https://www.geneva-academy.ch/joomlatools-files/docman-files/The%20Universal%20Periodic%20Review%20.pdf

សេចក្តីថ្លែងការណ៍រួម ក្នុងឱកាសនៃចិរវេលាត្រូវដាក់របាយការណ៍ពាក់កណ្តាលអាណត្តនៃយូ.ភី.អ សម្រាប់ប្រទេសកម្ពុជា ក្នុងខែកញ្ញា ឆ្នាំ២០២១[64]។

**កញ្ចប់ឧបករណ៍ សម្រាប់សង្គមស៊ីវិល អំពីការរាយការណ៍ពាក់កណ្តាលអាណត្តិ៖**

- ការរាយការណ៍ពាក់កណ្តាលអាណត្តិ នៃយូ.ភី.អ៖ ការធ្វើឲ្យដល់កម្រិតអតិបរមានៃការអនុវត្តប្រកបដោយចីរភាព ការអនុវត្តល្អៗ សម្រាប់ភាគីពាក់ព័ន្ធក្នុងដំណើរការ យូ.ភី.អ (២០១៨) https://www.upr-info.org/sites/default/files/general-document/pdf/upr_midterm_report_web_v1_high.pdf.

**ការពិនិត្យជាសកលតាមកាលកំណត់ យូ.ភី.អ ជុំបន្ទាប់ សម្រាប់ប្រទេសកម្ពុជា (ជុំទីបួន)៖**

- ក្នុងការត្រៀមរៀបចំសម្រាប់ការពិនិត្យជុំបន្ទាប់សម្រាប់ប្រទេសកម្ពុជា កាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់របាយការណ៍របស់សង្គមស៊ីវិល ត្រូវបានកំណត់ជាបឋម ក្នុងខែ កញ្ញា/តុលា ឆ្នាំ២០២៣[65]។
- យូ.ភី.អ ជុំបន្ទាប់ គឺជុំទីបួន សម្រាប់ប្រទេសកម្ពុជា មានកាលបរិច្ឆេទធ្វើឡើងក្នុងខែ**ឧសភា ឆ្នាំ ២០២៤**[66]។

### 3.4.2 សក្តានុពលរបស់ យូ.ភី.អ ក្នុងការរួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅប្រទេសកម្ពុជា

ផ្នែកនេះ រៀបរាប់អំពីទស្សនៈមួយចំនួនស្តីពីសក្តានុពលនិងតួនាទីនៃការចូលរួមជាមួយដំណើរការ យូ.ភី.អ ដើម្បីរួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅប្រទេសកម្ពុជា។

ក្នុងរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា បោះផ្សាយនៅខែសីហា ឆ្នាំ២០២១ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា លោកសាស្រ្តាចារ្យ Vitit Muntarbhorn ទទួលស្គាល់ពីតួនាទីនៃការចូលរួមរបស់ប្រទេសកម្ពុជាជាមួយដំណើរការ យូ.ភី.អ ថាជា"ការបើកទ្វារ" ទៅកាន់កំណែទម្រង់នានា ដើម្បីការការពារសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។

របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា សាស្រ្តាចារ្យ Vitit Muntarbhorn ខែសីហា ឆ្នាំ២០២១ https://undocs.org/A/HRC/48/79

**"ស្រ្តីស្រឡាញ់ស្រ្តី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងបុគ្គលអន្តរភេទ**
៦៣. បរិយាកាសនៅក្នុងប្រទេស មានលក្ខណៈបើកចំហគួរសមសម្រាប់បញ្ហាសិទ្ធិរបស់ស្រ្តីស្រឡាញ់ស្រ្តី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងបុគ្គលអន្តរភេទ។ ក៏ប៉ុន្តែ មានហេតុការណ៍មួយចំនួនទាក់ទងនឹងការរើសអើងនិងអំពើហិង្សា ឧទាហរណ៍ការសម្លុតតាំងពីវ័យក្មេង។ **ការចូលរួមរបស់ប្រទេសកម្ពុជា**

[64] Joint Statement by Civil Society Organizations: Step Up Efforts To Protect The Rights Of Lesbian, Gay, Bisexual, Transgender, Intersex, Queer (LGBTIQ) People In Cambodia, In Line With The Universal Periodic Review Recommendations Accepted By Cambodia. (27 September 2021) https://rockcambodia.org/joint-statement-upr-mtr-2021/.
[65] See UPR Info timeline for Cambodia https://www.upr-info.org/en/review/Cambodia
[66] https://www.upr-info.org/en/review/Cambodia

**ជាមួយនឹងដំណើរការ យូ.ភី.អ ក៏បានបើកទ្វារ ទៅកាន់កំណែទម្រង់ជាសក្តានុពល បែបស្ថាបនា មួយចំនួន ដែរ។** ទីមួយ មានលទ្ធភាពនៃការបង្កើតច្បាប់ស្តីពីការប្រឆាំងនឹងការរើសអើង ដែលអាចមានដាក់បញ្ចូល មូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ព្រមទាំងជួយការពារដល់សិទ្ធិរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងបុគ្គលអន្តរភេទ។ ទីពីរ មានលំហក្នុងការស្វែងរកនូវ លទ្ធភាព ដើម្បីបង្កើតច្បាប់ដែលទទួលស្គាល់អាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទដូចគ្នា។ ការតម្រង់ទិស ទាំងអស់នេះ ត្រូវការការពិគ្រោះយោបល់ពេញលេញនៅក្នុងប្រទេស ដោយតាមរយៈការចូលរួមរបស់ក្រុមពាក់ ព័ន្ធដែលបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ។

[…]

៧៩. សកម្មភាពមួយចំនួនអាចរៀបចំឡើងបាន […] អាចអញ្ជើញឲ្យមានកិច្ចសហប្រតិបត្តិការ៖ […] (គ) ការតាមដានបន្តការអនុវត្តនៃអនុសាសន៍នានាដែលប្រទេសកម្ពុជាបានទទួលយក នៅក្នុងការពិនិត្យ យូ.ភី.អ លើកចុងក្រោយ ជាពិសេសទាក់ទងជាមួយនឹងការអនុម័តច្បាប់ប្រឆាំងនឹងការរើសអើង ដែលនឹងផ្តល់ ការ ការពារដល់ស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងបុគ្គលអន្តរភេទ ព្រមទាំង ច្បាប់ដែលទទួលស្គាល់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា។”

អង្គការសង្គមស៊ីវិលនៅកម្ពុជា បានចូលរួមយ៉ាងសកម្មជាមួយដំណើរការយូ.ភី.អជុំទីបីសម្រាប់ប្រទេស កម្ពុជា ទៅលើបញ្ហាសិទ្ធិមនុស្សជាច្រើន ដោយរួមបញ្ចូលទាំង សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការ បង្ហាញយេនឌ័រ និងលក្ខណៈភេទផងដែរ។ ដោយឡែក សម្ព័ន្ធអង្គការសង្គមស៊ីវិលដែលធ្វើការលើសិទ្ធិនិន្នាការ ភេទ អត្តសញ្ញាណនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ បានចូលរួម យ៉ាងសកម្មជាមួយដំណើរការ យូ.ភី.អ នេះ តាមរយៈការរៀបចំការដាក់របាយការណ៍រួមគ្នា ក្នុងឆ្នាំ២០១៨[67] និងការតស៊ូមតិទៅកាន់ភាគីពាក់ព័ន្ធទាំងអស់ មុនដំណើរការពិនិត្យឡើងវិញនោះ ក៏ដូចជាក្រោយការត្រួត ពិនិត្យឡើងវិញ ក្នុងការគាំទ្រនិងលើកទឹកចិត្តដល់ដំណើរការអនុវត្តអនុសាសន៍ យូ.ភី.អ ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ដែលប្រទេស កម្ពុជាបានទទួលយក។ សមាជិកអង្គការសហគមន៍ឥន្ទនូ (រ៉ក់) បានឆ្លុះបញ្ចាំងទៅលើបទពិសោធន៍នេះ និង បានចែករំលែកនូវទស្សនៈរបស់ពួកគេទៅលើសក្តានុពលនិងតួនាទីនៃការចូលរួមជាមួយដំណើរការនេះ ក្នុងការ រួមចំណែកដល់ការការពារសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ នៅ ប្រទេសកម្ពុជា។

លី ពិសី, ហេង ជ័យលាភី និង Sally Low “ការតស៊ូមតិសម្រាប់គ្រួសារឥន្ទធនូនៅកម្ពុជា” *ព្រឹត្តិបត្រស្រាវជ្រាវច្បាប់អាស៊ីរបស់ប្រទេសអូស្ត្រាលី* (២០១៩) ភាគ២០ លេខ១ អត្ថបទទី១២៖ ទំ. ១៥១-១៦៣, https://papers.ssrn.com/sol3/papers.cfm?abstract_id=3489681

“[…] នៅចុងឆ្នាំ២០១៨ រ៉ក់ បានសម្រេចចិត្តចូលរួមក្នុងការសរសេររបាយការណ៍សង្គមស៊ីវិល ស្តីពីស្ថានភាពនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និង សិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជក្នុងប្រទេសកម្ពុជា ដាក់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

[67] Civil Society UPR Joint Submission: ‘Joint Submission to the UN Human Rights Council for the Third Universal Periodic Review of the Kingdom of Cambodia. SOGIESC & SRHR in Cambodia’, (2018) available at https://ilga.org/downloads/stakeholdersreport_CAMBODIA_UPR32.pdf.

សម្រាប់ការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទីបីសម្រាប់ប្រទេសកម្ពុជា។ នេះគឺជាលើកដំបូងសម្រាប់ប្រទេសកម្ពុជា ដែល យូ.ភី.អ ពិចារណាជាក់លាក់ទៅលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។ ដូច្នេះហើយ អង្គការរ៉ក់ មានចំណាប់អារម្មណ៍ថា វាជាការសំខាន់ណាស់ដែលត្រូវចូលរួម និងកសាងសាមគ្គីភាពជាមួយអង្គការសង្គមស៊ីវិលផ្សេងទៀត ដែលមានឆន្ទៈនៅក្នុងការលើកឡើងអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះ និងធ្វើឲ្យបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នាកាន់តែត្រូវបានគេមើលឃើញ។ បន្ថែមពីលើនេះទៀត យូ.ភី.អ ត្រូវបានលើកតម្លៃថាជាដំណើរការត្រួតពិនិត្យ រវាងរដ្ឋនិងរដ្ឋដោយមានបំណងលើកទឹកចិត្ត និងជួយជ្រោមជ្រែងដល់រដ្ឋនានា ក្នុងការធ្វើឲ្យប្រសើរឡើងនូវ ការអនុវត្តរបស់ខ្លួន (UPR, <www.upr-info.org>)។ ដើម្បីកសាងទំនុកចិត្ត ការឈ្វេងយល់គ្នាទៅវិញទៅមក និងតម្លាភាព សហអ្នកនិពន្ធនៃរបាយការណ៍អង្គការសង្គមស៊ីវិលនេះ ព្រមព្រៀងក្នុងការចែករំលែករបាយការណ៍នេះ ទៅដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រដ្ឋាភិបាល មុននឹងដាក់របាយការណ៍នេះ។ ការដាក់របាយការណ៍រួមគ្នានេះបានលើកឡើងអំពីកង្វះការការពារផ្លូវច្បាប់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ថាជាចំណុចខ្វះខាតមួយនៃសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នា (សម្ព័ន្ធអង្គការសង្គមស៊ីវិល, ២០១៨)។

សម្រាប់រ៉ក់ ដំណើរការ យូ.ភី.អ មិនមែនជាចំណុចចុងបញ្ចប់នោះទេ ប៉ុន្តែ វាជាមធ្យោបាយមួយក្នុងការលើកកម្ពស់ការយល់ដឹង និងក្នុងការកសាងសម្ព័ន្ធភាព។ ការឆ្លុះបញ្ចាំងផ្ទៃក្នុងទៅលើដំណើរការនេះ នាំទៅដល់ការធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោម៖

ទីមួយ សមាជិករ៉ក់ មានការចាប់អារម្មណ៍យ៉ាងខ្លាំងដែលបានដឹងថា យូ.ភី.អ មិនមែនជាដំណើរការតែមួយទិសសម្រាប់តែការរិះគន់ពីខាងក្រៅមកលើប្រទេសកម្ពុជានោះទេ ផ្ទុយទៅវិញ មានការឆ្លើយតបគ្នាទៅវិញទៅមកនៅក្នុងដំណើរការ យូ.ភី.អ នេះ ដើម្បីឲ្យរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យនេះ មានឳកាសអាចផ្តល់អនុសាសន៍ទៅឲ្យរដ្ឋផ្សេងទៀតនាពេលក្រោយដែរ (OHCHR, <www.ohchr.org.>)។

ទីពីរ អ្នកស្រឡាញ់ភេទដូចគ្នាច្រើនជាង ៨០ នាក់ដែលមកពីបណ្តាញរ៉ក់ ក៏មានឱកាសចូលរួមក្នុងដំណើរការពិគ្រោះយោបល់ ដែលពួកគេអាចបញ្ចេញសំឡេងរបស់ខ្លួនឲ្យអ្នកផ្សេងបានដឹងឮនិងឲ្យមានការគោរព។ ពួកគេបានរៀនសូត្រអំពីដំណើរការ យូ.ភី.អ នេះ និងទទួលបានបទពិសោធន៍នៃសាមគ្គីភាព និងការពង្រឹងភាពអង់អាចក្នុងការតស៊ូមតិរួមគ្នា នៅពេលដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជាអ្នកដឹកនាំ និងធ្វើជាម្ចាស់ទៅលើដំណើរការតស៊ូមតិនោះ។

ទីបី ដំណើរការផលិតរបាយការណ៍បានលើកទឹកចិត្តឲ្យមានការយល់ដឹងនិងការពិភាក្សាកាន់តែប្រសើរឡើងអំពីលក្ខណៈភប់ប្រសព្វរវាង សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី និងសិទ្ធិទទួលបានសុខភាព។ ជាលទ្ធផល ក្រុមការងារសិទ្ធិស្ត្រីមួយចំនួន បានទទួលស្គាល់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។

ជាចុងក្រោយ ការពិគ្រោះយោបល់ថ្នាក់ជាតិដំណាលគ្នាដែលដឹកនាំដោយរាជរដ្ឋាភិបាល និងរៀបចំដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រាជរដ្ឋាភិបាល បានផ្តល់នូវវេទិកាមួយ ក្នុងការចងបណ្តាញជាមួយ និងបញ្ចុះបញ្ចូលតំណាងក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាលមួយចំនួន ព្រមទាំងពង្រីកទំនាក់ទំនងរបស់ខ្លួនជាមួយនឹងស្ថាប័នទាំងនោះទៀតផង។

រ៉ក់ យល់ឃើញថា ដំណើរការនេះបង្កើតនូវលំហមួយសម្រាប់អង្គការសង្គមស៊ីវិលក្នុងការលើកឡើងនូវក្តីបារម្ភ និងផ្តល់ជាអនុសាសន៍។ ដំណើរការនេះ ក៏ផ្តល់ឱកាសដល់អ្នកចូលរួម ឲ្យបាន ស្តាប់ឮផែនការនិងនីតិវិធីដែលស្នើឡើងដោយរាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងបរិយាប័ន្ន (រាជរដ្ឋាភិបាលកម្ពុជា ២០១៤)។"

### 3.4.3 តួនាទីរបស់ភាគីពាក់ព័ន្ធនីមួយៗ ក្នុងការគាំទ្រដល់ការអនុវត្តអនុសាសន៍ យូ.ភី.អ

ទោះបីជារដ្ឋក្រោមការពិនិត្យជាសកលតាមកាលកំណត់ ជាអ្នកទទួលខុសត្រូវចម្បងក្នុងការអនុវត្តអនុសាសន៍ យូ.ភី.អ ដែលបានទទួលយកនៅពេលត្រួតពិនិត្យ ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសក៏ដោយ ក៏ភាគីពាក់ព័ន្ធនានា អាចដើរតួនាទីក្នុងការគាំទ្រដល់ការអនុវត្តអនុសាសន៍ យូ.ភី.អ នេះដែរ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណាក់កាលនៃការអនុវត្តនេះ មានសារៈសំខាន់ណាស់ក្នុងការគាំទ្រឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពទៅលើអនុសាសន៍របស់ យូ.ភី.អ ហើយ វានឹងរួមចំណែកដល់ការផ្លាស់ប្តូរវិជ្ជមាន ទៅលើស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេស ដោយរួមបញ្ចូលទាំងស្ថានភាពសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទដែរ។

| តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការគាំទ្រដល់ការអនុវត្តអនុសាសន៍ យូ.ភី.អ | |
|---|---|
| រដ្ឋក្រោមការពិនិត្យ (កម្ពុជា) | • រដ្ឋស្ថិតក្រោមការពិនិត្យ មានតួនាទីទទួលខុសត្រូវចម្បង ក្នុងការអនុវត្តអនុសាសន៍ដែល ទទួលយកនៅក្នុងដំណើរការ យូ.ភី.អ[68] ដោយរួមបញ្ចូលទាំង ការតាក់តែងគោលនយោបាយ និងការបង្កើតច្បាប់ ព្រមទាំងផ្អែកទៅលើការពិគ្រោះយោបល់ជាទៀងទាត់ ប្រកបដោយ អត្ថន័យនិងបរិយាប័ន្ន ជាមួយសង្គមស៊ីវិល។<br>• ការអនុវត្តល្អៗសម្រាប់ការអនុវត្តអនុសាសន៍ យូ.ភី.អ ដោយរដ្ឋក្រោមការពិនិត្យ រួមមាន៖<br>    • ការបង្កើតយន្តការថ្នាក់ជាតិមួយ សម្រាប់ការធ្វើរបាយការណ៍ និងតាមដានបន្ត ដែលមានលក្ខណៈអចិន្ត្រៃយ៍និងអន្តរក្រសួង ដើម្បីសម្របសម្រួលនិងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ (អង្គការសង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ រដ្ឋសភា និងប្រព័ន្ធយុត្តិធម៌)<br>    • ការបង្កើតផែនការសកម្មភាពសិទ្ធិមនុស្ស ដើម្បីកំណត់អត្តសញ្ញាណក្រសួងដែលទទួលខុសត្រូវក្នុងការអនុវត្ត និងរៀបចំបង្កើតសូចនាករដើម្បីវាស់វែងការអនុវត្ត[69]។<br>• ស្ថាប័នរបស់រាជរដ្ឋាភិបាលគ្រប់កម្រិតទាំងអស អាចចូលរួមក្នុងការអនុវត្តអនុសាសន៍ យូ.ភី.អ បាន។ ការអនុវត្តល្អៗ បានគូសបញ្ជាក់ដ៏គួរឲ្យកត់សម្គាល់ អំពីតួនាទីរបស់ សមាជិកសភាផងដែរ[70]។ |
| រដ្ឋដែលផ្តល់អនុសាសន៍ ដល់ | សហគមន៍អន្តរជាតិ ដោយរួមបញ្ចូលទាំងរដ្ឋដែលបានផ្តល់អនុសាសន៍ អាចជួយជ្រោមជ្រែងក្នុងការអនុវត្តអនុសាសន៍ យូ.ភី.អ ទាំងនោះដែរ[71]៖ |

[68] A/HRC/RES/5/1. Para 33. "The outcome of the universal periodic review, as a cooperative mechanism, should be implemented primarily by the State concerned and, as appropriate, by other relevant stakeholders."
[69] UPR Info, The Butterfly Effect - Spreading good practices of UPR implementation, (2016) https://www.upr-info.org/sites/default/files/general-document/pdf/2016_the_butterfly_effect.pdf
[70] Miloon Kothari, Study on emerging Good Practices from the Universal Periodic Review (UPR), (2021). https://www.upr-info.org/sites/default/files/general-document/pdf/emerging_upr_goodpractices.pdf Page 15-16.
[71] A/HRC/RES/5/1. Para 36. The international community will assist in implementing the recommendations and conclusions regarding capacity-building and technical assistance, in consultation with, and with the consent of, the country concerned.

| | |
|---|---|
| ប្រទេសកម្ពុជា | • រដ្ឋដែលបានផ្តល់អនុសាសន៍ អាចបន្តកិច្ចសន្ទនាទ្វេភាគីជាមួយនឹងរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យនោះ ដោយរួមបញ្ចូលការស្នើសុំព័ត៌មានលម្អិតបន្ថែមទៀតទៅលើផែនការអនុវត្ត យូ.ភី.អ។ រដ្ឋដែលផ្តល់អនុសាសន៍ទាំងនោះ ក៏អាចផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋស្ថិតនៅ ក្រោមការពិនិត្យ ក្នុងការអនុវត្តអនុសាសន៍យូ.ភី.អ ផងដែរ។<br>• រដ្ឋដែលផ្តល់អនុសាសន៍ទាំងនោះ អាចគាំទ្រដល់អង្គការសង្គមស៊ីវិល ក្នុងកិច្ចប្រឹងប្រែង រួមចំណែកដល់ការអនុវត្តអនុសាសន៍។ |
| ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ទីភ្នាក់ងារអង្គការសហប្រជាជាតិត្រូវបានលើកទឹកចិត្តឲ្យដាក់បញ្ចូលការអនុវត្តអនុសាសន៍ យូ.ភី.អ ទៅក្នុងការងាររបស់ខ្លួននៅកម្រិតប្រទេសនីមួយៗ[72]<br>• ទីភ្នាក់ងារអង្គការសហប្រជាជាតិ អាចផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ទៅដល់រាជរដ្ឋាភិបាល លើយន្តការ ក្នុងការអនុវត្តអនុសាសន៍ យូ.ភី.អ និងសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល[73]។ |
| អង្គការសង្គមស៊ីវិល អង្គការតាមមូលដ្ឋាន អ្នកការពារសិទ្ធិមនុស្ស | អង្គការសង្គមស៊ីវិល គឺជាភាគីពាក់ព័ន្ធដ៏សំខាន់នៅក្នុងដំណើរការយុត្តិធម៌ដែលអាចរួមចំណែកដល់ការអនុវត្តអនុសាសន៍ យូ.ភី.អ ដែរ[74]<br>• អង្គការសង្គមស៊ីវិល អាចសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីគាំទ្រដល់ការអនុវត្តអនុសាសន៍ទាំងនោះ និងអាចតាមដានឃ្លាំមើល និងរាយការណ៍អំពីការអនុវត្តអនុសាសន៍ទាំងនោះដែរ។ |
| អ្នកសារព័ត៌មាន និងតួអង្គដទៃ ក្នុង ប្រព័ន្ធផ្សព្វផ្សាយ | អ្នកសារព័ត៌មាន និងតួអង្គដទៃនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ អាចដើរតួនាទីមួយចំនួនក្នុងការអនុវត្តអនុសាសន៍ យូ.ភី.អ ដោយរួមបញ្ចូលទាំង៖<br>• ផ្តល់ព័ត៌មានទាន់ពេលវេលា ទៅដល់សាធារណជនអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល នៅក្នុងអំឡុងពេលនៃដំណើរការ យូ.ភី.អ ដោយរួមបញ្ចូលទាំងការផលិតនូវខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយផ្សេងគ្នា ដូចជា ទម្រង់សរសេរ សំឡេង រូបភាព សោតទស្សន៍ ដើម្បីជូនដំណឹងដល់សាធារណជនអំពីប្រធានបទទាំងអស់នេះ។<br>• តាមដានឃ្លាំមើលការរីកចម្រើននៃការអនុវត្ត ក៏ដូចជាការដាក់បញ្ចូលអង្គការសង្គមស៊ីវិលប្រកបដោយអត្ថន័យ នៅក្នុងដំណើរការ យូ.ភី.អ ព្រមទាំងធ្វើរាយការណ៍អំពីរឿងរ៉ាវជោគជ័យនិង ឧបសគ្គនានារបស់ភាគីពាក់ព័ន្ធទាំងអស់[75]។ |

[72] Miloon Kothari, Study on emerging Good Practices from the Universal Periodic Review (UPR), (2021). https://www.upr-info.org/sites/default/files/general-document/pdf/emerging_upr_goodpractices.pdf Page 17-18.
See also: OHCHR, Maximizing the use of Universal Periodic Review at Country Level: Practical Guidance https://www.ohchr.org/Documents/HRBodies/UPR/UPR_Practical_Guidance.pdf
[73] UPR Info, The Butterfly Effect - Spreading good practices of UPR implementation, (2016) https://www.upr-info.org/sites/default/files/general-document/pdf/2016_the_butterfly_effect.pdf
[74] A/HRC/RES/5/1. Para 33
[75] https://www.upr-info.org/sites/default/files/general-document/pdf/upr_info_cso_compendium_en.pdf page 35.

| | |
|---|---|
| អ្នកសិក្សាស្រាវជ្រាវ | ដើម្បីគាំទ្រដល់ការអនុវត្តអនុសាសន៍ យូ.ភី.អ តួអង្គក្នុងវិស័យសិក្សាធិការ (ដោយរួមបញ្ចូលទាំងអ្នកស្រាវជ្រាវ គ្រូនៅសាកលវិទ្យាល័យ និងនិស្សិតសាកលវិទ្យាល័យ) អាចៈ<br>• ធ្វើការស្រាវជ្រាវអំពីការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស ដែលកើតចេញមកពីការអនុវត្តអនុសាសន៍ យូ.ភី.អ ដើម្បីប៉ាន់ប្រមាណអំពីភាពជោគជ័យនៃយន្តការនេះ និងដើម្បីកំណត់ឲ្យបានអំពីឧបសគ្គ ឬ ភាពខ្វះខាតនានា ក៏ដូចជាដើម្បីធានាថាលទ្ធផលនៃការស្រាវជ្រាវ ត្រូវបានផ្សព្វផ្សាយ តាមមធ្យោបាយជាច្រើន ដើម្បីបង្កើនចំណេះដឹងរបស់សាធារណជនអំពី យូ.ភី.អ។<br>• បញ្ចូលការពិភាក្សាអំពីយន្តការ យូ.ភី.អ ជាផ្នែកមួយនៃមុខវិជ្ជាសិទ្ធិមនុស្សនៅសាកលវិទ្យាល័យ[76]។ |
| សាធារណជនទូទៅ | សាធារណជនទូទៅក៏អាចរៀនសូត្រអំពីដំណើរការនិងអនុសាសន៍ យូ.ភី.អ ដែលរាជរដ្ឋាភិបាលរបស់ខ្លួនបានទទួលយក តាមរយៈការតាមដានទៅលើ សេចក្តីរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ឬចូលរួមនៅក្នុងការពិគ្រោះយោបល់។ សាធារណជនទូទៅ អាចចូលរួមនៅក្នុងការជជែកវែកញែកដេញដោលជាសាធារណៈជុំវិញបញ្ហាដំណើរការ យូ.ភី.អ និងអនុសាសន៍ យូ.ភី.អ និងបញ្ហាសិទ្ធិមនុស្សដែលបង្កប់នៅពីក្រោយ។ |

[76] UPR Info, The Butterfly Effect - Spreading good practices of UPR implementation, (2016) https://www.upr-info.org/sites/default/files/general-document/pdf/2016_the_butterfly_effect.pdf page 41.